# សិក្សាបទមនុស្សល្អ



# ពាក្យផ្ដើម

មនុស្សយើងគ្រប់គ្នា ចង់បានជាមនុស្សល្អ ប៉ុន្តែមនុស្សល្អមិនមែនល្អឯងៗនោះទេ លុះត្រាតែខំប្រឹងទូន្មានកាយវាចាចិត្តទប់ស្កាត់នូវកិលេសផ្សេងៗ ដែលកិលេសហ្នឹងឯងវាតែងតែដឹកនាំកាយវាចាចិត្ត ឱ្យប្រព្រឹត្តខុស ហើយអ្នកប្រព្រឹត្តខុសនោះឈ្មោះថា ជាមនុស្សមិនល្អ ជាមនុស្សស្អុយក្នុង ។

ការកសាងខ្លួនឱ្យបានជាមនុស្សល្អ មិនមែនជាការងាយទេ ប៉ុន្តែក៏មិនមែនផុតវិស័យនៃមនុស្ស



គ្រប់គ្នាដែរ ព្រោះធម្មជាតិបានរៀបចំឱ្យមនុស្សកើតដោយ **កុសលវិបាកបដិសន្ធិ** ដែលជាកំណើតខ្ពង់ខ្ពស់ខុសអំពីកំណើតសត្វតិរច្ឆាន ដូច្នេះមនុស្សណា ប្រាថ្នាកសាងខ្លួនឱ្យបានល្អ ខំសិក្សារៀនសូត្រដើម្បីឱ្យបានដឹងនូវផ្លូវល្អផ្លូវអាក្រក់ សមាគមជាមួយសប្បុរសជានិច្ច បដិបត្តិយកឈ្នះកិលេសក្នុងសន្តានចិត្ត មិនប្រព្រឹត្តទុច្ចរិត មនុស្សនោះពិតជាបានទទួលនូវវត្ថុបំណងដូចសេចក្តីប្រាថ្នា គឺថាបានជាមនុស្សល្អពិតប្រាកដមែន ។

សហគមន៍ធម្មទាន មានសេចក្តីសង្ឃឹមថាកូនសៀវភៅតូចមួយនេះ អាចបានជាជំនួយដល់គំនិត និង ស្មារតីនៃបុរសស្ត្រីក្មេងចាស់ គ្រហស្ថបព្វជិតពិតជាពុំខាន បើសិនជាបានអានរួចហើយ ។



សហគមន៍ធម្មទាន មានបំណងជួយឱ្យមនុស្សបានល្អ ដើម្បីសេចក្តីសុខចម្រើននៃជីវិតក្នុងសង្គមគ្រួសារ និង ប្រទេសជាតិ ព្រមទាំងលោកទាំងមូល ។

**១រោជ ខែពិសាខ ព.ស ២៥៤៥**

**សហគមន៍ធម្មទាននៃពុទ្ធបរិស័ទ**

*បោះពុម្ព ២០.០០០ក្បាល*

*សម្រាប់ជាធម្មទាន*

## ការខារជាជីវិតរបស់មនុស្ស

αមនុស្សត្រូវធ្វើការតាមតួនាទី បើមិនដូច្នោះទេ គឺមិនអាចបានជាមនុស្សល្អឡើយ វារមែងធ្លាក់ចូលក្នុងចំណោមមនុស្សអន់ មនុស្សទ្រមក់ មនុស្សវង្វេង ហើយបើសិនជាទៅធ្វើអំពើអាក្រក់វិញនោះ ឈ្មោះថាជាមនុស្សគម្រក់តែម្តង ឬឈ្មោះថាជាមនុស្ស**ស្លាប់ទាំងរស់ ស្ទួយទាំងស្រស់** ។

ខ្លាចលំបាកហើយខ្ជិល មិនរួចអំពីសេចក្តីលំបាកឡើយ ខ្វះសេចក្តីអត់ធន់ការងារមិនបានល្អ ខ្វះការតស៊ូការងារមិនសម្រេច ព្រោះសេចក្តីប្រហែសធ្វេស ការងារដែលចេះស្ទាត់ហើយនោះ ត្រឡប់ទៅជាបរាជ័យដូចបុគ្គលល្ងង់ខ្លៅ ។



## មាតិកាធម៌


| ល.រ | ឈ្មោះវគ្គនៃធម៌ | ទំព័រ |
|---|---|---|
| ១_ | តួនាទីបុត្រធីតា ៥សិក្ខាបទ................ | ១ |
| ២_ | តួនាទីមាតាបិតា ៥សិក្ខាបទ................ | ១១ |
| ៣_ | តួនាទីសិស្ស ៥សិក្ខាបទ...................... | ២១ |
| ៤_ | តួនាទីលោកគ្រូអាចារ្យ ៥សិក្ខាបទ......... | ៣១ |
| ៥_ | តួនាទីស្វាមី សិក្ខាបទ.......................... | ៤១ |
| ៦_ | តួនាទីភរិយា ៥សិក្ខាបទ....................... | ៥១ |
| ៧_ | តួនាទីមិត្តល្អ ៥សិក្ខាបទ...................... | ៦១ |
| ៨_ | តួនាទីមិត្តមានឧបការៈ ៥សិក្ខាបទ........ | ៧១ |
| ៩_ | តួនាទីចៅហ្វាយនាយ៥សិក្ខាបទ........... | ៨១ |
| ១០_ | តួនាទីទាសៈ និងកម្មករ៥សិក្ខាបទ......... | ៩១ |





| | | |
|---|---|---|
| ១១_ | តួនាទីពុទ្ធបរិស័ទជាគ្រហស្ថ៥សិក្ខាបទ.. | ១០១ |
| ១២_ | តួនាទីសមណព្រាហ្មណ៌ ៦សិក្ខាបទ.... | ១១១ |
| ១៣_ | បទគួរយល់ដឹងក្នុងតួនាទី .................. | ១២៣ |
| ១៤_ | សតិសម្បជញ្ញៈក្នុងការងារ ................ | ១៣៣ |
| ១៥_ | មនុស្សចេះគិត ................................ | ១៤៩ |
| ១៦_ | មង្គល ៣៨ប្រការ ........................... | ១៦៦ |
| ១៧_ | ភាសិតកំណាព្យ .............................. | ១៧១ |

# តួនាទីបុត្តធីតា ៥សិក្ខាបទ

## តួនាទីបុត្តធីតា

**សិក្ខាបទទី១** : បុត្តធីតាគប្បីសិក្សាថា អាត្មាអញ មាតាបិតាបានចិញ្ចឹមរក្សាមកហើយ នឹងចិញ្ចឹមមាតាបិតាវិញ ។

កើតមកជាមនុស្ស បើគ្រាន់តែនឹករលឹកដល់អំពើល្អដែលអ្នកដទៃបានធ្វើមកលើខ្លួន មិនឃើញហើយនោះ ចាំបាច់និយាយធ្វើអ្វីចំពោះសេចក្តីល្អផ្សេងៗទៀតថាអាចនឹកឃើញដើម្បីសន្សំកពូនក្នុងសន្តានទៅបាន ។ បក្សីស៊ីផ្លែពោធិ៍ជ្រៃអស់ហើយហើរចេញមិនបែរក្រោយ រឿងនេះមិនគួរឱ្យតិះដៀលទេ ព្រោះវាជាធម្មតារបស់សត្វតិរច្ឆាន ប៉ុន្តែមនុស្សយើងវិញបើធ្វើរបៀបហ្នឹងពោល



គឺមិនបែរក្រោយដោយការនឹករលឹកដល់គុណ ដែលអ្នកដទៃមានមាតាបិតាជាដើម បានធ្វើហើយនូវប្រយោជន៍សុខចម្រើនកើតកើនដល់ខ្លួននោះ វាគួរឱ្យតិះដៀលខ្លាំងណាស់ ព្រោះមនុស្សយើងមិនមែនជាសត្វតិរច្ឆានឯណា។

ធ្វើបុណ្យដាក់បាត្រក្រាបសំពះព្រះនៅវត្តគឺពិតជាល្អ មានចិត្តស្មោះសសន្សំគុណធម៌ក្នុងសន្តាន ប៉ុន្តែសូមកុំភ្លេចព្រះនៅផ្ទះ ព្រះដ៏មានគុណធ្ងន់ ជាព្រះអរហន្តគឺមាតាបិតា សូមកូនប្រុសស្រីចិញ្ចឹមបីបាច់ថែរក្សា ក្រាបសំពះមាតាបិតាកុំគប្បីអៀនអន់ កុំឱ្យក្តៅក្រហាយស្តាយក្នុងកាលជាខាងក្រោយ ។

## តួនាទីបុត្តធីតា

**សិក្ខាបទទី២** : បុត្តធីតាគប្បីសិក្សាថា អាត្មាអញនឹងជួយធ្វើការងារឱ្យមាតាបិតា ដោយសេចក្តីមិនខ្ជិលច្រអូសឡើយ ។

សេចក្តីខ្ជិលជាអបាយមុខប្រការ១ គឺជាប្រធាននៃសេចក្តីវិនាសនូវប្រយោជន៍គ្រប់យ៉ាង ដូច្នេះ បើយើងខ្ជិលធ្វើការឱ្យអ្នកដទៃ ប៉ុន្តែមិនគួរខ្ជិលធ្វើសេចក្តីល្អឱ្យដល់ខ្លួនឯងឡើយ ។ សត្វឆ្មាយំទារចំណី ចង់ឱ្យយើងធ្វើសេចក្តីល្អជាមួយវា សត្វសុនខជាដើមក៏ដូចគ្នា ចំណែកខ្លួនយើងវិញ តើយំទារឱ្យអ្នកណាធ្វើសេចក្តីល្អឱ្យ ?

មនុស្សគ្រប់គ្នាប្រាថ្នាចង់បានសេចក្តីល្អអំពីអ្នក



ដទៃ ប៉ុន្តែសូមកុំភ្លេចថា មិនមានអ្នកណាស្រឡាញ់យើងជួយយើង ជាងខ្លួនយើងឡើយ ដូច្នេះ យើងត្រូវប្រាថ្នាសេចក្តីល្អគ្រប់យ៉ាងអំពីខ្លួនឯង ការបំរើអ្នកមានគុណគឺជាសម្បត្តិដ៏ប្រពៃ ជាសេចក្តីល្អមួយដែលអ្នកធ្វើត្រូវបានទទួលដោយខ្លួនឯងយ៉ាងពិតប្រាកដ ។

ការងារប្រពៃគឺជាព្រះស្ថិតក្នុងសន្តានចិត្ត ពិតជាជួយសត្វលោកឱ្យរួចផុតចាកបាបកម្ម និង ពៀរវេរាមានផលផុតចាកទុក្ខភ័យ សូមកូនប្រុសស្រីរក្សាព្រះក្នុងផ្ទះ និង ព្រះក្នុងសន្តានចិត្ត កុំគប្បីធ្វេសប្រហែសឡើយ ។



## តួនាទីបុត្តធីតា

**សិក្ខាបទទី៣** : បុត្តធីតាគប្បីសិក្សាថា អាត្មាអញនឹងតម្កល់តម្កើងនូវវង្សត្រកូលឱ្យបានល្អ ។

ចរិយាមារយាទជារឿងសំខាន់ណាស់ បុត្តធីតាគប្បីរក្សាខ្លួនដោយសីលធម៌ ការរក្សាសីល ជាការធ្វើសេចក្តីល្អឱ្យដល់ខ្លួនឯង ដោយមិនចាំបាច់អស់ទុនឡើយ គ្រាន់តែអាស្រ័យលើស្មារតីថែទាំខ្លួន សិក្សាស្វែងយល់អំពីសុជីវធម៌ សណ្តាប់ធ្នាប់ល្អ ព្រមដោយការបដិបត្តិដោយប្រពៃ ក៏បានសម្រេចផលកម្រៃដ៏ប្រសើរ គឺបានធ្វើជាមនុស្សល្អម្នាក់ លើកស្ទួយវង្សត្រកូលផង ប្រទេសជាតិរបស់ខ្លួនផង សង្គមមនុស្សទាំងមូលផង ។

កូនប្រុសស្រីទាំងឡាយ អ្នកទាំងឡាយកុំខ្លាចសីលឡើយ កុំគិតថាសីលជារឿងលំបាកឱ្យសោះ សីលមិនមែនជាសត្រូវរបស់កូនទេ កិលេសក្នុងចិត្តរបស់កូនទេតើ ដែលជាសត្រូវធ្វើនូវការបៀតបៀនដល់កូននោះ ចំណែកសីលគឺជាមិត្តល្អគ្រប់ពេល ជាសិរីមង្គលពិតប្រាកដ សូមកូនពិចារណាផងចុះ ។

ការតម្កល់តម្កើងនូវវង្សត្រកូល ក៏គឺជាការដែលកូនប្រុសស្រីតម្កល់ខ្លួនឯងឱ្យប្រពៃ ខ្មីឃ្មាតសិក្សារៀនសូត្រផ្លូវលោកផ្លូវធម៌ ចេះជួយសង្គ្រោះអ្នកដទៃសាងស្នាដៃប្រកបដោយសីលធម៌ ។



# តួនាទីបុត្តធីតា

**សិក្ខាបទទី៨** : បុត្តធីតាគប្បីសិក្សាថា អាត្មាអញនឹងបដិបត្តិឱ្យបានសមគួរជាអ្នកទទួលនូវទ្រព្យមរតក ។

មាតាបិតាទោះបីមានទ្រព្យតិចច្រើនប៉ុនណាៗក្តី គ្មានអ្វីដែលគួរឱ្យសង្ស័យឡើយ បើថាគាត់កំណាញ់ក៏តែជាមួយនឹងអ្នកដទៃប៉ុណ្ណោះ ឯចំណែកខាងកូនរបស់គាត់វិញនោះ មានប៉ុន្មានទុកឱ្យទាំងអស់ ទុកឱ្យដោយចិត្តរីករាយកក់ក្តៅជាទីបំផុត ដូច្នេះ ចូរកូនប្រុសស្រីកុំគប្បីធ្វើក្តីអស់សង្ឃឹមឱ្យដល់មាតាបិតា ត្រូវខំបដិបត្តិខ្លួនឱ្យរឹងប៉ឹង មាននូវមារយាទល្អសម្តែងនូវការសមគួរឱ្យ



ជាទីទុកចិត្តដល់មាតាបិតា ដាច់ខាតកុំមើលងាយទ្រព្យមរតកឱ្យសោះ ទោះបីតិចតួច ឬ មិនប្រណីតយ៉ាងណាក្តី ព្រោះក្នុងមរតកនោះ បានបង្កប់ទៅដោយមនោសញ្ចេតនាដ៏ជ្រាលជ្រៅ ប្រកបដោយព្រហ្មវិហារធម៌ អាណិតស្រឡាញ់ និង មេត្តាដ៏ខ្លាំងក្លា កាយវិការរឹងប៉ឹងតែចិត្តទន់ភ្លន់ស្រទន់ដូចមេឃស្រទំចំពោះបុត្តភ្ញាស្ងួនពិសី ។

សូមកូនប្រុសស្រីគប្បីទទួលឱ្យបាន នូវមរតកពិសេស គឺព្រហ្មវិហារធម៌របស់មាតាបិតា ហើយគប្បីពង្រីកចែកឱ្យដល់ជនដទៃដោយក្តីមេត្តាករុណាធំទូលាយបន្តិចម្តងៗ ។

# តួនាទីបុត្តធីតា

**សិក្ខាបទទី៥** : បុត្តធីតាគប្បីសិក្សាថា អាត្មាអញត្រូវធ្វើបុណ្យឧទ្ទិសទក្ខិណាទាន ដល់មាតាបិតា ដែលធ្វើកាលកិរិយាទៅកាន់បរលោកហើយ ។

ទក្ខិណាទានគឺទានដែលអ្នកធ្វើជឿកម្មជឿផល ហើយបានធ្វើដល់ទក្ខិណេយ្យបុគ្គល ទក្ខិណេយ្យបុគ្គល គឺបុគ្គលមានគុណធម៌ខ្ពង់ខ្ពស់ដូចជាសីលគុណជាដើម ជាបុគ្គលសមគួរនឹងទទួលនូវទក្ខិណាទាន ចំណែកពាក្យថា ទក្ខិណានុប្បទាន គឺជាអំណោយបុណ្យ បានដល់ការឧទ្ទិសនូវទក្ខិណាទានឱ្យដល់អ្នកដែលទៅកាន់បរលោក ។

ការធ្វើបុណ្យឧទ្ទិសឱ្យអ្នកដទៃ ជាសេចក្តីល្អពីរ



យ៉ាង ម្យ៉ាងគឺបុណ្យថ្នាក់ទានមានភាពជាឥស្សរៈលើកិលេស ម្យ៉ាងទៀត គឺបុណ្យបត្តិទាន មានចិត្តល្អប្រកបដោយមេត្តា ឬការដឹងគុណចែកបុណ្យឧទ្ទិសកុសល អំពើល្អទាំងពីរយ៉ាងនេះ គឺអ្នកធ្វើបានឧទ្ទិសឱ្យខ្លួនឯងទាំងស្រុង សម្រាប់ជួយខ្លួនឱ្យរួចអំពីភាពជាមនុស្សអាក្រក់។

បើកូនចៅប្រាថ្នាពរ គឺរបស់ដែលប្រសើរ សូមកូនចៅបំពេញហេតុបានដល់កុសល ឱ្យសមគួរដល់ផលទើបអាចទទួលពរបាន ។



# តួនាទីមាតាបិតា ៥សិក្ខាបទ

## តួនាទីមាតាបិតា

**សិក្ខាបទទី១** : មាតាបិតាគប្បីសិក្សាថា អាត្មាអញត្រូវហាមឃាត់កូន ក្នុងកាលដែលកូនធ្វើនូវអំពើបាបផ្សេងៗ ។

សម្បត្តិមរតកមាសប្រាក់លុយកាក់ ដីធ្លីស្រែចំការ ទោះបីច្រើនប៉ុនណាក៏មិនមានតម្លៃដូចជាឱវាទទូន្មានប្រៀនប្រដៅឡើយ ម៉ែឪហាមកូនកុំឱ្យធ្វើបាបគឺជាការចែកសុគតិភពឱ្យកូនផង ជួយសង្គ្រោះមនុស្សសត្វយ៉ាងច្រើនឱ្យបានរួចផុតអំពីការបៀតបៀនរបស់កូនផង សមជាព្រះប្រោសសត្វលោកដែលមានឧបនិស្ស័យបានមកជាកូនប្រុសស្រីផង ជាព្រះព្រហ្ម ជាទេវតា ជា



បុព្វាចារ្យពិតប្រាកដរបស់កូនផង ។

សូមមាតាបិតាកុំស្រឡាញ់កូនជ្រុលហួស រហូតដល់មិនហ៊ានហាមឃាត់កូន ដែលប្រព្រឹត្តធ្វើនូវបាបកម្មផ្សេងៗ តួនាទីមួយនេះសំខាន់ណាស់ ក្នុងសង្គមសត្វមានជីវិតទាំងអស់ សូមពឹងពាក់លើអ្នកដែលជាមាតាបិតាសូមលោកមេត្តាអប់រំកូនឱ្យបានល្អ ប្រឹងប្រែងឱ្យអស់សមត្ថភាព ។

ចរិយាមារយាទពាក្យសម្ដីគំនិតថោកថ្លៃ រស់ក្នុងជីវិតរាល់ថ្ងៃ ជាឧបនិស្ស័យបង្ហាត់កូន ដូច្នេះ ម៉ែឪត្រូវប្រយ័ត្នខ្លួនឯងផង ។

៙៙✧៚៚



## តួនាទីមាតាបិតា

**សិក្ខាបទទី២** : មាតាបិតាគប្បីសិក្សាថា អាត្មាអញត្រូវញុំាងកូនប្រុសស្រីឱ្យតាំងនៅក្នុងអំពើល្អ ។

ការមិនធ្វើបាបនោះ ជាការល្អហើយ ប៉ុន្តែអំពើល្អនៅមានទៀត ដូចជាកល្យាណធម៌ ៥យ៉ាង ដែលជាគូគ្នានឹងការវៀរចាកបញ្ចវេរា បានដល់ មេត្តាករុណាគូគ្នាជាមួយនឹងការមិនសម្លាប់សត្វ១ ការចិញ្ចឹមជីវិតដោយប្រពៃគូគ្នាជាមួយនឹងការមិនធ្វើចោរ១ មានសេចក្ដីសន្ដោសចេះសង្គ្រោះឱ្យតម្លៃក្នុងនាមជាភរិយាល្អ ស្វាមីប្រពៃគូគ្នាជាមួយនឹងការមិនផិតក្បត់ គឺមិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ១ និយាយពាក្យពិតជាវចីសច្ចៈគូគ្នា

ជាមួយនឹងការមិនកុហក១ ចម្រើនស្មារតីដឹងខ្លួនដោយប្រពៃគួគ្នាជាមួយនឹងការមិនបរិភោគនូវទឹកស្រវឹង១ ។ សូមមាតាបិតាកុំបន្ធូរបន្ថយ កុំបណ្តែតបណ្តោយក្នុងតួនាទីរបស់ខ្លួន សូមមេត្តាជួយបំពាក់គ្រឿងអលង្ការគឺកល្យាណធម៌ឱ្យដល់បុត្តធីតាកុំគប្បីខានឡើយ ។

ការបញ្ចូលគំនិតល្អព្រមដោយគុណធម៌ទៅក្នុងខ្លួនរបស់កូន ប្រសើរជាងពេជ្រទាំងគ្រាប់ ។



## តួនាទីមាតាបិតា

**សិក្ខាបទទី៣** : មាតាបិតាគប្បីសិក្សាថា អាត្មាអញត្រូវឱ្យកូនរៀនសូត្រសិល្បសាស្ត្រ ។

សិល្បសាស្ត្រគឺជាចំណេះដឹងសម្រាប់ប្រកបរបរចិញ្ចឹមជីវិត មានចំណេះខាងជាងជាដើម កាលឱ្យកូនសិក្សារៀនសូត្រចំណេះផ្លូវលោក ក៏ត្រូវឱ្យកូនយល់ដឹងតាមផ្លូវធម៌ព្រះពុទ្ធសាសនាផង ជាប្រយោជន៍ដើម្បីកុំឱ្យប្រើប្រាស់ចំណេះផ្លូវលោកក្នុងអំពើទុច្ចរិត ចិញ្ចឹមជីវិតខុសដោយប្រការផ្សេងៗ ។

បើកូនប្រុសស្រីត្រូវការសម្បត្តិ ត្រូវការទីពឹងសម្រាប់រស់ ត្រូវកុំខ្ជិលច្រអូស ត្រូវកុំសេពគប់ជាមួយ



មនុស្សមិនល្អ ត្រូវវៀរអបាយមុខគ្រប់យ៉ាងឱ្យឆ្ងាយ ហើយកុំប្រព្រឹត្តនូវអ្វីៗដែលជាការបំផ្លិចបំផ្លាញនូវស្មារតីរបស់ខ្លួនឯងឱ្យសោះ ត្រូវប្រឹងសិក្សារៀនសូត្រ និងបដិបត្តិនូវហេតុ-បច្ច័យនៃសម្បត្តិទាំងពួង ព្រោះសម្បត្តិទាំងពួងមានការងារជាហេតុសំខាន់ សូមកូនប្រុសស្រីគាំទ្រជីវិតបរិសុទ្ធដោយចិត្តរីករាយ ។

ទ្រព្យសម្បត្តិចំណេះវិជ្ជាខាងក្រៅត្រូវអាស្រ័យគុណធម៌ខាងក្នុង ទើបមានប្រយោជន៍ពិត ជាម្លប់របស់ជីវិត រស់នៅមានតម្លៃ ។

## តួនាទីមាតាបិតា

**សិក្ខាបទទី៤** : មាតាបិតាគប្បីសិក្សាថា អាត្មាអញត្រូវចាត់ចែងឱ្យបានសមគួរ ក្នុងរឿងដណ្ដឹងប្រពន្ធឱ្យកូន ឬ ទុកដាក់កូនឱ្យមានប្ដី ។

មិនមែនជាការរីករាយ ដើម្បីចងកូនប្រុសស្រីទុកក្នុងវដ្ដៈឡើយ ប៉ុន្តែជាការជួយរៀបសម្រួលក្នុងដំណើរផ្លូវ ដែលកូនត្រូវតែទៅនោះឱ្យបានសមរម្យ ។

ក្នុងរឿងនេះ ក៏វាអាចមានចម្រូងចម្រាស ព្រោះហេតុទាស់អធ្យាស្រ័យគ្នារវាងមាតាបិតា និងបុត្តធីតា ដូច្នេះ នៅក្នុងសិក្ខាបទទី៤ របស់មាតាបិតានេះ មិនមែនត្រូវធូររលុងទេ ប៉ុន្តែតឹងរឹងពេកទៅក៏អាច



មានបញ្ហាធ្ងន់ធ្ងរកើតឡើងបានដែរ ដូចមានពាក្យមួយឃ្លាបានចែងថា « *សេចក្ដីស្នេហាជាផ្នូរកប់ព្រលឹងមនុស្ស* » បានសេចក្ដីថាជាការស្លាប់ចិត្ត ហើយពិតជាលំបាកនឹងស្រោចស្រង់ណាស់ ដូច្នេះ ការបង្វែរឱ្យខុសទិសដៅម៉ែឪត្រូវតែប្រយ័ត្ន ក្រែងលោធ្ងន់លើសដើម ។

ធ្វើអ្វីៗក៏ត្រូវតែឆ្លាតដែរ ទើបមិនសូវប្រទះនូវបញ្ហាស្មុគស្មាញ កើតមកជាមនុស្សត្រូវសិក្សាស្វែងយល់ត្រូវសាងសមត្ថភាពក្នុងតួនាទីរបស់ខ្លួន ។



## តួនាទីមាតាបិតា

**សិក្ខាបទទី៥** : មាតាបិតាគប្បីសិក្សាថា អាត្មាអញត្រូវចែកទ្រព្យឱ្យកូនក្នុងសម័យគួរ ។

សម័យដែលគួរមានពីរយ៉ាង ដែលសម្រាប់មាតាបិតាឱ្យទ្រព្យសម្បត្តិដល់កូន ម្យ៉ាងគឺនិច្ចសម័យសម្រាប់ចាយផងធ្វើបុណ្យផង ជានិច្ចរាល់ពេលកំណត់ ម្យ៉ាងទៀត គឺកាលសម័យ បានដល់ពេលកូនប្រុសស្រីមានប្ដីប្រពន្ធ ឬឱ្យទ្រព្យមរតកផ្សេងៗនៅពេលដែលដឹងថាខ្លួននឹងស្លាប់ ។

សូមកូនប្រុសស្រីកុំភ្លេចថា ជើងដៃសាច់សរសៃឈាមឆ្អឹងឆ្អែង រួមទាំងជីវិតកំពុងរស់នៅនេះ គឺជា

មរតកសម្បត្តិដែលមាតាបិតាបានចែកឱ្យហើយ សឹងពោរពេញទៅដោយមេត្តាករុណា និង សេចក្តីស្រឡាញ់ ចំណេះវិជ្ជាផ្លូវលោកផ្លូវធម៌ ក៏ត្រូវម៉ែឪចែកឱ្យដោយសព្វគ្រប់ដែរ សុំឱ្យកូនកាត់បន្ថយនូវតណ្ហាដែលត្រូវការសម្បត្តិទ្រព្យច្រើនៗអំពីម៉ែឪទៅ បើចេះតែទុកនៅមិនបន្ថយទេនោះ វានឹងបិទបាំងនូវគុណម៉ែឪទាំងអស់ បែរជាឱ្យពោលទោសឪពុកម្តាយរបស់ខ្លួនឯងទៅវិញ ។

ចំណេះវិជ្ជាព្រមដោយចរិយាមារយាទល្អ និង គុណធម៌របស់មនុស្ស ជាមរតកដ៏ប្រសើរ ។



# តួនាទីសិស្ស ៥សិក្ខាបទ

## តួនាទីសិស្ស

**សិក្ខាបទទី១** : សិស្សគប្បីសិក្សាថា អាត្មាអញត្រូវក្រោកគោរពទទួលលោកគ្រូអាចារ្យ ។

បដិសណ្ឋារកិច្ចដោយសេចក្តីគោរព ដោយចិត្តជ្រះថ្លាប្រារព្ធចំពោះគុណដែលមានក្នុងគ្រូអាចារ្យ គឺជាសិរីសួស្តីរបស់សិស្ស ។

ក្នុងសិក្ខាបទទី១របស់សិស្សនេះ មិនចំពោះតែការក្រោកឈរទទួលប៉ុណ្ណោះទេ កិច្ចការដែលត្រូវទទួលនៅមានច្រើនទៀត រួមសេចក្តីគោរពទាំងអស់មកហៅថា អបចាយនៈជាពូជនៃត្រកូលខ្ពង់ខ្ពស់ ជាគុណធម៌ដ៏ស្រស់បស់ក្នុងសន្ដាន ។

មនុស្សឆ្លាតរមែងទុកនូវភាពរឹងប៉ឹង ការចេះដឹង និង គុណធម៌របស់ខ្លួនខាងក្នុង ប៉ុន្តែខាងក្រៅបញ្ចេញនូវភាពទន់ភ្លន់ឱនលំទោន នេះគឺជាមនុស្សទន់ក្រៅតែរឹងប៉ឹងខាងក្នុង ខុសអំពីមនុស្សល្ងង់ ដែលចូលចិត្តអួតអាងរឹងក្រញាងចេញមកខាងក្រៅ តែខាងក្នុងវិញគ្មានសមត្ថភាពអ្វីសោះ ទន់ជ្រាយដូចដីភក់ប៉ប៊ិចប៉ប៉ាច់ មិនមានអ្វីពិត ពាក្យសំដីមិនទៀងទាត់ ប្រាកដដូចជាផ្គរអត់ភ្លៀង ឬ រ៉ូងរ៉ាងដូចប៉ោតអត់ទឹក ។

ការគោរពគុណគឺមហាកុសលដែលជាធម្មជាតិឆ្លាតឈ្លាស បែងចែកគុណទោសឱ្យផ្សេងពីគ្នា ជាធម៌ទន់ភ្លន់ជាមួយគុណតែរឹងប៉ឹងជាមួយទោស ។

ៜៜ✧ៜៜ



# គួនាទីសិស្ស

**សិក្ខាបទទី២** : សិស្សគប្បីសិក្សាថា អាត្មាអញត្រូវឧបដ្ឋាកលោកគ្រូអាចារ្យ ។

ការគាល់បម្រើគ្រូអាចារ្យ ជាការចុះទុនបន្តិចបន្តួចបន្ទាប់បន្សំ ប៉ុន្តែផលកម្រៃវិញគឺសេចក្តីល្អជាបុណ្យផង ចំណេះដឹងសម្រាប់ដោះស្រាយបញ្ហាជីវិតផង សរុបរួមច្រើនក្រៃកន្លង ជាការងារចម្រើនកើនប្រយោជន៍ដោយពិត ។

មនុស្សយើងត្រូវខំប្រញាប់ធ្វើសេចក្តីល្អនៅក្នុងថ្ងៃនេះ គឺឥឡូវនេះឯង និង ធ្វើរឿយៗតទៅទៀត ត្រូវសន្សំបុណ្យឱ្យបានច្រើន ត្រូវចាំទុកថា ពេលវេលាមិនសួរ



សម្បូរទេ បើចេះតែបង្អែបង្អង់រ៉ែរ៉ៃម៉ោងពេលយប់ថ្ងៃក៏អស់ទៅ អាយុក៏កន្លងទៅ ចំណែកបុណ្យកុសលអំពើល្អមិនចម្រើនឡើងសោះអីចឹង ជីវិតនឹងមានតម្លៃនៅត្រង់ណា ព្រោះថាតម្លៃនៃជីវិតវាស្ថិតនៅត្រង់បុណ្យគឺអំពើល្អដែលខ្លួនបានធ្វើទុកនោះឯង រឿងនេះពិតមែនតែបរលោកមិនមែនជាការទិញដូរ ប៉ុន្តែបរលោកនៃជីវិតវាជាផលរបស់ការងារ បើការងារល្អជីវិតក៏ថ្លៃ បរលោករមែងរុងរឿង ។

មនុស្សយើងមានជីវិតគឺមានការងារ មនុស្សល្អធ្វើតែការងារណាដែលប្រាសចាកទោស ស្វែងរកទ្រព្យផង ស្វែងរកគុណធម៌បុណ្យកុសលមកដាក់ខ្លួនផង ។

ៜៜ✧ៜៜ

# តួនាទីសិស្ស

**សិក្ខាបទទី៣ :** សិស្សគប្បីសិក្សាថា អាត្មាអញត្រូវស្តាប់ឱវាទអំពីគ្រូអាចារ្យដោយល្អ ។

ពាក្យថាស្តាប់ដោយល្អគឺស្តាប់ឱ្យយល់ ហើយពិចារណាតាមហេតុ និង ផល យ៉ាងនេះរមែងបាននូវបញ្ញា សូមឱ្យសិស្សទាំងឡាយស្រឡាញ់គ្រូដោយស្មោះ គោរពការចេះដឹង និង គុណធម៌ ម្យ៉ាងទៀត ត្រូវចេះសិក្សាអំពីធម្មជាតិជុំវិញខ្លួន មិនចំពោះតែមនុស្ស ឬ សត្វ ឬ រុក្ខជាតិឡើយ ព្រោះថា ធម្មជាតិគ្រប់យ៉ាងអាចបង្រៀនយើងបាន ឬអាចជាកញ្ចក់សម្រាប់ស្អិតស្អាងខ្លួនយើងឱ្យបានល្អ គឺជាកញ្ចក់ដែលមានតម្លៃពិសេស ។



សិស្សមិនត្រូវខឹងក្រោធចំពោះឱវាទរបស់គ្រូ ហើយក៏មិនត្រូវបដិបក្ខជាមួយនឹងរបស់ជុំវិញខ្លួន ត្រូវមានស្មារតីអត់ធន់ចម្រើនបញ្ញាសិក្សាអំពីធម្មជាតិ ចូលរៀនក្នុងសាលាលោក៦ គឺលោកភ្នែក លោកត្រចៀក លោកច្រមុះ លោកអណ្តាត លោកកាយ និង លោកចិត្ត ឱ្យជានិច្ចជាប្រចាំ ហើយត្រូវសិក្សាកុំឱ្យក្រៅអំពីហេតុ និងផល ព្រោះហេតុនិងផល ជាច្បាប់របស់ធម្មជាតិ ជាសច្ចធម៌ មានហេតុទើបមានផលកើតឡើង ហេតុយ៉ាងណានោះកែប្រែពុំបានជាដាច់ខាត បើអត់ហេតុអត់បច្ច័យទេ មិនមានអ្វីមកបង្គាប់បញ្ជាឱ្យមានធម្មជាតិក្នុងលោកនេះបានឡើយ ។

៙៙✧៚៚



# តួនាទីសិស្ស

**សិក្ខាបទទី៤ :** សិស្សគប្បីសិក្សាថា អាត្មាអញត្រូវប្រណិប័តន៍គ្រូដោយធ្វើការងារ ទោះបីការងារនោះតូចតាចបន្តិចបន្តួចក៏ដោយ ក៏មិនត្រូវទុកឱ្យលោកគ្រូអាចារ្យធ្វើខ្លួនឯងដែរ ។

ការជ្រោមជ្រែងការគាំទ្រ ការសម្តែងសេចក្តីគោរពដោយបម្រើការងារ ជាការអនុមោទនាចំពោះគុណបុណ្យ ជាការបំរើដ៏ប្រសើរដោយចិត្តទន់ភ្លន់ លើកស្នួយរបស់ធ្ងន់ដើម្បីប្រយោជន៍ដល់ជនទាំងពួង ។

មនុស្សឆ្លាតរមែងស្វែងរកគុណធម៌មកទុកក្នុងខ្លួន សាងគុណចម្រើនប្រយោជន៍ឱ្យដល់សង្គមមនុស្ស

សង្គមសត្វ ប្តេជ្ញាតាំងចិត្តមិនដុតសង្គម ពោលគឺមិនធ្វើឱ្យសង្គមសត្វលោកក្តៅក្រហាយ ដោយសារខ្លួនឯងម្នាក់ឡើយ ហើយគោរពស្រឡាញ់គាំទ្រនូវបុគ្គលណាដែលមានសមត្ថភាព អាចផ្តល់ប្រយោជន៏ឱ្យសង្គមតូចធំបានសុខក្សេមក្សាន្ត ។

សូមមនុស្សលោកគ្រប់គ្នា លើកនូវទង់ជ័យរបស់មនុស្សគឺគុណធមិ តាមពិតមានតែគុណធមិប៉ុណ្ណោះ ដែលធ្វើឱ្យមនុស្សយើង មានជីវិតប្រសើរជាងពពួកសត្វតិរច្ឆាន។



## តួនាទីសិស្ស

**សិក្ខាបទទី៥** : សិស្សគប្បីសិក្សាថា អាត្មាអញត្រូវរៀនសិល្បវិជ្ជាអំពីលោកគ្រូអាចារ្យដោយសេចក្តីគោរព ។

មិនចំពោះតែវិជ្ជាអ្វីនោះទេ បើសិស្សមានសមត្ថភាពរៀនចេះបានច្រើនមុខវិជ្ជាគឺរឹតតែល្អ គុណទោសរបស់មុខវិជ្ជានៅលើអ្នកប្រើជាសំខាន់ បើប្រើក្នុងផ្លូវត្រូវគឺជាគុណ តែបើប្រើក្នុងផ្លូវខុសគឺជាទោស ។

ការប្រកបនូវមុខវិជ្ជាអ្វីមួយដើម្បីចិញ្ចឹមជីវិតក្តី ដើម្បីជាប្រយោជន៏ដល់សង្គមក្តី ត្រូវមើលឆន្ទៈខ្លួនឯងឱ្យជាក់ច្បាស់ ព្រោះឆន្ទៈគឺសេចក្តីពេញចិត្តក្នុងការងារជា



កម្លាំងចិត្ត អាចញ៉ាំងសេចក្តីព្យាយាមឱ្យប្រព្រឹត្តជាប់តមិនដាច់ ជាហេតុឱ្យសម្រេចនូវប្រយោជន៏ បើមិនដូច្នេះវានឹងជួបប្រទះនូវការអស់ពេលឥតប្រយោជន៏ អស់ទាំងទុនក្នុងរឿងផ្សេងៗទៀតផង ។

ម្យ៉ាងទៀត ការចាប់នេះចាប់នោះមិនឆ្ពោះត្រង់ណា វាអាចមិនបានការទាំងអស់ផងដែរ មុខវិជ្ជាសូម្បីតែម្យ៉ាងគត់ឱ្យតែចេះស្ទាត់ ប្រព្រឹត្តមិនដាច់ដោយសេចក្តីមិនប្រមាទ ប្រៀបបាននឹងកំណប់ទ្រព្យ ។

# តួនាទីលោកគ្រូអាចារ្យ ៥សិក្ខាបទ

## តួនាទីលោកគ្រូអាចារ្យ

**សិក្ខាបទទី១** : លោកគ្រូអាចារ្យគប្បីសិក្សាថា អាត្មាអញត្រូវដឹកនាំសិស្សឱ្យល្អ ។

រឿងល្អរបស់មនុស្សគឺមារយាទល្អ សណ្តាប់ធ្នាប់ល្អ មានសុជីវធម៌ មានអធ្យាស្រ័យយោគយល់ ចេះឱ្យអភ័យ ។ល។ កើតមកជាមនុស្សមានការងារល្អច្រើនណាស់ដែលត្រូវធ្វើ ដូច្នេះ ដើម្បីឱ្យបានទៅជាមនុស្សល្អពិត ត្រូវប្រឹងរៀនសូត្រឱ្យចេះអំពីមនុស្សធម៌ សីលធម៌ សុជីវធម៌ក្នុងសង្គម អានសៀវភៅដែលមានប្រយោជន៍ឱ្យច្រើន ហើយព្យាយាមប្រព្រឹត្តកែលំអខ្លួន កសាងខ្លួនរឿយៗរាល់ថ្ងៃ ។



ការកសាងខ្លួនឱ្យកាន់តែល្អដោយគុណធម៌ វាផុតវិស័យនៃសត្វតិរច្ឆាន ប៉ុន្តែត្រូវបានធ្លាក់ចុះមកជាលាភរបស់មនុស្ស ដូច្នេះ សូមកុំឱ្យឱកាសកន្លងហួសពេលវេលាមានតម្លៃណាស់ ត្រូវចាប់ផ្តើមពីឥឡូវនេះ គឺមុនដំបូងត្រូវរៀនឱ្យចេះដឹងជាដំណឹងយ៉ាងប្រសើរថា ខ្លួនឯងមានកំហុស ម្យ៉ាងទៀតចាំបាច់ត្រូវដឹងថា មានកិលេសព្រោះនៅល្ងង់ បន្ទាប់អំពីដឹងហើយត្រូវព្យាយាមកែនូវកំហុស និង ព្យាយាមចម្រើនបញ្ញា នេះឯងជាវិស័យអ្នកកសាងខ្លួន ។

ᨠᨠ✧ᨩᨩ

## គុណនាទីលោកគ្រូអាចារ្យ

**សិក្ខាបទទី២** : លោកគ្រូអាចារ្យគប្បីសិក្សាថា អាត្មាអញត្រូវបង្រៀនសិស្សដោយល្អ ។

ការតាំងចិត្តឱ្យសិស្សចេះដឹងដោយមេត្តា ជាការប្រឹងប្រែងមួយជួយដល់សង្គមមនុស្ស ឈ្មោះថាគ្រូមកអំពីបាលីថា គរុ ប្រែថា ធ្ងន់ *(គរ > គ្រ +ុ > ូ = គ្រូ)* អ្នកដែលមានចិត្តធ្ងន់ អ្នកដែលគួរគេគោរព គឺអ្នកបង្ហាត់បង្រៀនចំណេះវិជ្ជាផ្សេងៗឱ្យសិស្សបានចេះដឹង ។ ពាក្យថា អាចារ្យ មកអំពីបាលីថា *អាចរិយ* ប្រែថា អ្នកប្រដៅ ឬ បង្ហាត់មារយាទ អ្នកប្រព្រឹត្តល្អ អ្នកកាន់ត្រឹមត្រូវ អ្នកប្រព្រឹត្តអំពើជាប្រយោជន៍ដល់សិស្ស ឬ អ្នកដែលសិស្ស



ត្រូវប្រព្រឹត្តដោយសេចក្តីគោរព ។

ការបង្រៀនសិស្សឱ្យចេះដឹង ល្មមសិស្សអាចពឹងខ្លួនឯងបាន ជាការឱ្យអភ័យដ៏ក្រៃលែង ព្រោះសេចក្តីល្ងង់បណ្តាលនាំឱ្យមានទុក្ខសោក សេចក្តីទុក្ខគឺជាភ័យធំរបស់សត្វទាំងឡាយ ។

អភ័យទានគួរមនុស្សគ្រប់រូបរៀនធ្វើឱ្យបានជាទម្លាប់ ព្រោះវានាំឱ្យកើតការសប្បាយចិត្តយ៉ាងប្រសើរដល់អ្នកធ្វើទានប្រភេទនេះ ។



## គុណនាទីលោកគ្រូអាចារ្យ

**សិក្ខាបទទី៣** : លោកគ្រូអាចារ្យគប្បីសិក្សាថា អាត្មាអញត្រូវបង្រៀន និង ប្រដៅសិស្សឱ្យចេះត្រឹមត្រូវក្នុងសិល្បសាស្ត្រសព្វគ្រប់ ។

មុខវិជ្ជាសម្រាប់ចិញ្ចឹមជីវិត ត្រូវបានមាតាបិតាបង្ហាត់បង្រៀនផង បញ្ជូនកូនឱ្យរៀននឹងលោកគ្រូអាចារ្យផង សម័យសព្វថ្ងៃមាតាបិតាត្រូវចំណាយប្រាក់អស់ច្រើនណាស់ដើម្បីឱ្យកូនរៀនសូត្រ កូនប្រុសស្រីត្រូវនឹករលឹកដល់កម្លាំងញើសឈាមរបស់មាតាបិតា ហើយប្រឹងប្រែងឧស្សាហ៍រៀនសូត្រ ដើម្បីជាប្រយោជន៍ខ្លួនឯងផង សង្គមគ្រួសារផង ប្រទេសជាតិមាតុភូមិផង ។

លោកគ្រូអាចារ្យឈ្មោះថាបុព្វការីរបស់សិស្ស ទាំងឡាយ សំខាន់ត្រង់មេត្តាដល់សិស្ស មានសេចក្តីអនុគ្រោះចង់ឱ្យសិស្សចេះដឹងពិតប្រាកដ ត្រង់ដែលការបូជាគុណដោយទេយ្យធម៌ផ្សេងៗដែលសិស្សបានធ្វើនោះ មិនជាបញ្ហា កុំតែប៉ងប្រាថ្នាវាជាការហើយស្រេច ព្រោះមនុស្សលោករស់នៅដោយសារអាហារ រស់ហើយមានកម្លាំងកាលណា ទើបអាចធ្វើនូវកិច្ចការតាមតួនាទីទៅបាន ។

ꩰꩰ✧ꩱꩱ



# តួនាទីលោកគ្រូអាចារ្យ

**សិក្ខាបទទី៤** : លោកគ្រូអាចារ្យគប្បីសិក្សាថា អាត្មាអញត្រូវលើកតម្កើងសិស្សក្នុងទីប្រជុំមិត្តអាមាត្យ ។

ការសរសើរលើកតម្កើងដោយចិត្តស្មោះ ដោយមេត្តាប្រាថ្នាឱ្យកម្លាំងចិត្ត សរសើរតាមការពិត ត្រង់ចំណុចដែលគួរសរសើរ ពេលស្ងាត់កំបាំងជួយប្រាប់នូវកំហុស ជួយកែកុំឱ្យជ្រុលជ្រួស បើក្នុងទីប្រជុំនោះចង់ពោលទោស ត្រូវពោលជាទូទៅ កុំចុចសំដៅចំឈ្មោះ ដូចនេះ សិស្សអាចដឹងនូវកំហុសបានដោយសប្បាយចិត្ត ការដឹងកំហុសហើយរីករាយនឹងកែលំអ រមែងបានដល់



នូវភាពរុងរឿង ដូចព្រះចន្ទចេញផុតចាកពពក ។

លាភ យស សរសើរ សុខ ជាសម្បុកនៃកិលេស ដោយការប្រមាទធ្វេស កិលេសចម្រើនមិនដឹងខ្លួន មិនស្គាល់កិលេស មិនឃើញសត្រូវនៅក្នុងចិត្ត តាមការពិតចិត្តពេញដោយតម្រេកការប្រកាន់ហួងហែង រហូតដល់ហ៊ានឈ្លោះទាស់ទែងកន្លែងអញកន្លែងឯង សូម្បីតែវត្តអារាមភ្នំល្អាងក៏អាងយ៉ាងយកជារបស់ខ្លួនដែរ ។

ដើម្បីកុំឱ្យសត្រូវគឺកិលេសស៊កសៀតចូលមកក្នុងចិត្តតូចតាចល្អិតល្មោចរឿយៗ រហូតប៉ុនភ្នំក៏នៅតែសំគាល់ថា អាត្មាអញជាអ្នកបរិសុទ្ធនោះ ត្រូវអាស្រ័យសេចក្តីមិនប្រមាទ ។

ꩰꩰ✧ꩱꩱ

## តួនាទីលោកគ្រូអាចារ្យ

**សិក្ខាបទទី៩** : លោកគ្រូអាចារ្យគប្បីសិក្សាថា អាត្មាអញត្រូវការពារសិស្សក្នុងទិសទាំងពួង ។

សិក្ខាបទដែលភិក្ខុបដិបត្តិបានត្រឹមត្រូវ រមែងរក្សាការពារនូវភិក្ខុនោះផង រក្សាការពារនូវព្រះពុទ្ធសាសនាផង យ៉ាងណាមិញ ការដឹកនាំឱ្យសិស្សល្អ ការបង្រៀនដោយល្អ ការបង្ហាត់សិល្បសាស្ត្រជាដើម គឺលោកគ្រូអាចារ្យមានការតាំងចិត្តការពារសិស្ស ក្នុងទីទាំងពួង ដោយសេចក្ដីថា ឱ្យសិស្សមានទីពឹង យ៉ាងនោះឯង គឺសំដៅយកត្រង់ទឹកចិត្តមេត្តាករុណាព្រមដោយការផ្ដល់ចំណេះវិជ្ជាផ្សេងៗ ការពារសិស្សកុំឱ្យវង្វេងស្រវឹង



នឹងសិល្បសាស្ត្រ ហើយប្រព្រឹត្តនូវអំពើផ្ដេសផ្ដាសបៀតបៀនអ្នកដទៃដោយប្រការណាមួយនោះ ។

អន្តរាយមកតាមផ្លូវណា ត្រូវការពារត្រង់ផ្លូវនោះដោយប្រយ័ត្នជាទីបំផុត អំពើអាក្រក់សៅហ្មងដែលអ្នកផងទាំងពួងតិះដៀល មិនមែនជាផលវិបាករបស់កម្មទេ ដូច្នេះអាចការពារបាននូវកម្មអាក្រក់លាមកសៅហ្មងនោះ ដោយស្មារតីប្រុងប្រយ័ត្ន មិនអាងទីស្ងាត់គិតថាអ្នកដទៃមិនឃើញ ត្រូវខ្លាចបាបកម្មជាងខ្លាចអ្នកដទៃមានប្រក្រតីត្រេកអរក្នុងសេចក្ដីមិនប្រមាទ ។



# តួនាទីស្វាមី ៥សិក្ខាបទ

## តួនាទីស្វាមី

**សិក្ខាបទទី១ :** ស្វាមីគប្បីសិក្សាថា អាត្មាអញត្រូវរាប់អាននាង ឱ្យតម្លៃនាង លើកតម្កើងនាង ថាជាភរិយាពេញមុខ ។

បានកើតមកជាមនុស្សគ្រប់គ្នា គឺជាស្នាដៃពិតប្រាកដរបស់ខ្លួនឯង ដែលជាអ្នកមានបុណ្យបានធ្វើទុកហើយ មិនមែនព្រោះការសូកប៉ាន់ ឬ ព្រោះការភាន់ច្រឡំដោយប្រការណាមួយនោះទេ ដូច្នេះ គួររាប់អានមនុស្សទាំងពួងដែលមានស្នាដៃពូកែអំពីជាតិមុនមក ។

ភរិយាគឺជាមនុស្សស្រីដែលមានប្ដីជាអ្នកចិញ្ចឹម មានប្ដីជាម្ចាស់លើ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ មានប្ដី



ជាធំក្នុងការគ្រប់គ្រង ដូច្នេះ ស្វាមីត្រូវគោរពតួនាទីរបស់ខ្លួនជាអ្នកចិញ្ចឹម ជាម្ចាស់ និង ជាអ្នកធំក្នុងការគ្រប់គ្រងថែទាំ ឱ្យដល់នារីម្នាក់ដែលខ្លួនបានយកនាងជាភរិយាហើយនោះ យ៉ាងនេះ ទើបសមនឹងឈ្មោះថា ភស្ដា ស្វាមី ប្ដី ។

ស្វាមីត្រូវចម្រើនមេត្តាទៅរកភរិយា និង ការអាណិតឱ្យបានច្រើន ព្រោះនាងបានចេញចាកអំពីត្រកូលចោលម៉ែឪបងប្អូនមីងមា តាមមកយកយើងម្នាក់គត់ជាគ្នា ប្រគល់កាយផ្ញើជីវិតឱ្យដល់បុរសម្នាក់ជាស្វាមីគ្រប់គ្រងជំនួសម៉ែឪនាង ។

ᨠᨠ✧ᨠᨠ



## តួនាទីស្វាមី

**សិក្ខាបទទី២ :** ស្វាមីគប្បីសិក្សាថា អាត្មាអញមិនត្រូវមើលងាយនាងជាភរិយាឡើយ ។

ព្រមយកប្រពន្ធដូចព្រមចូលកាន់សមរភូមិ មិនមែនមិនដឹងរឿងរ៉ាវអ្វីសោះហើយចេះតែប្រថុយនោះទេ អ្នកចម្បាំងគេរៀនយុទ្ធសាស្ត្រ ចំណែកអ្នកគ្រប់គ្រងផ្ទះក៏ត្រូវចេះក្បួនសម្រាប់គ្រប់គ្រងដែរ ត្រូវច្បាំងជាមួយចិត្តអាក្រក់របស់ខ្លួនផង ទប់ទល់ដោះស្រាយចំពោះកិលេសរបស់ប្រពន្ធផង ការពារវិបត្តិភយន្តរាយផ្សេងៗទៀតផង គឺជាការគ្រប់គ្រងដោយអំណត់អត់ធន់ជាទីបំផុត ដាច់ខាតកុំយកការមើលងាយមើលថោកមកធ្វើ

ចម្បាំង វាមិនពូកែឡើយ ការមើលងាយសត្រូវវានាំឱ្យប្រហែស សេចក្ដីប្រហែសជាចំណុចចាញ់ ។

ធម្មតាប្ដីប្រពន្ធសុទ្ធតែជាអ្នកមានកិលេស ហើយជាធម្មតារបស់កិលេសរមែងនាំមកនូវទុក្ខ ដូច្នេះទើបកិលេសឈ្មោះថាជាសត្រូវ តើវាលំបាកប៉ុនណាទៅចំពោះជីវិតដែលរស់នៅក្នុងជំរុំនៃសត្រូវនោះ ណ្ហើយចុះទ្រាំទៅ! ហើយត្រូវខំទូន្មានចិត្ត ទម្លាប់ឱ្យចេះស្មោះត្រង់នឹករលឹករឿយៗដល់សេចក្ដីល្អរវាងគ្នានិងគ្នា កុំមើលងាយគ្នាឱ្យសោះ សុទ្ធតែជាអ្នកជាប់ខ្នោះទាំងអស់គ្នាទេ ត្រូវមានមេត្តាដល់គ្នាទើបប្រពៃ។

ꩡꩡ✧ꩡꩡ



# តួនាទីស្វាមី

**សិក្ខាបទទី៣ :** ស្វាមីគប្បីសិក្សាថា អាត្មាអញមិនត្រូវប្រព្រឹត្តក្បត់ចិត្តប្រពន្ធឡើយ ។

ការស្មោះត្រង់ចំពោះគ្នានិងគ្នា គឺជាបេះដូងអាពាហ៍ពិពាហ៍ ស្វាមីទោះបីមានការខ្វះខាតក្នុងមុខនាទីដទៃខ្លះ ប៉ុន្តែរក្សាការស្មោះចំពោះភរិយាទុកបានដោយល្អ មិនក្បត់ចិត្ត មិនច្រប្លូកច្របល់ក្នុងកាមគុណជាមួយស្ត្រីដទៃ អាចចាត់ទុកបានថាជាស្វាមីដែលល្អម្នាក់កម្រ រក ជាស្វាមីអាចធ្វើឱ្យក្រុមគ្រួសារកក់ក្ដៅមាននូវសេចក្ដីសុខ រស់នៅជាមួយគ្នារហូតដល់ចាស់ មានសម្រស់ល្អដល់កូនចៅ ដូចមេអំបៅលំអសួនផ្កា ។



អណ្ដាត និង ធ្មេញរមែងតែងតែប៉ះខ្ទប់គ្នាខ្លះជាធម្មតា ប៉ុន្តែបាននៅជាមួយគ្នាដោយល្អ ធ្មេញជាអ្នកទំពាអាហារ រីឯអណ្ដាតជាអ្នកត្រឡប់នូវអាហារនោះបង្វិលចុះបង្វិលឡើង រហូតលេបចូលពោះបានរស់ទាំងអស់គ្នា យ៉ាងណាមិញ ប្ដីប្រៀបដូចធ្មេញ ប្រពន្ធប្រៀបដូចអណ្ដាត កាលនៅជាមួយគ្នា ធ្វើការជាមួយគ្នា ក៏រមែងទាស់ទែងថ្នាំងថ្នាក់អាក់អន់នឹងគ្នាខ្លះពុំខាន ក៏យ៉ាងនោះដែរ ប៉ុន្តែការស្មោះត្រង់ប្រកបដោយមេត្តាករុណាប្រៀបដូចជាអាហារក្នុងមាត់ ។

ꩡꩡ✧ꩡꩡ

## តួនាទីស្វាមី

**សិក្ខាបទទី៤ :** ស្វាមីគប្បីសិក្សាថា អាត្មាអញត្រូវប្រគល់ឥស្សរិយៈ គឺភាពជាធំឱ្យដល់នាងជាភរិយា ចាត់ចែងកិច្ចការងារក្នុងផ្ទះ ។

ឥស្សរិយយសរបស់ស្វាមី ធ្វើឱ្យស្ត្រីជាភរិយាទន់ភ្លន់ចិត្ត ទោះបីនាងមានរូបល្អយ៉ាងណាក្តី មានទ្រព្យមរតករបស់នាងច្រើនក្តី មានញាតិច្រើនក្តី មានសីលធម៌ចរិយាមារយាទល្អប្រពៃក្តី រួមទាំងកម្លាំងបុត្រទៀតក្តី សរុប ៥យ៉ាងនេះចូលគ្នា ក៏មិនមានកម្លាំងស្មើ នឹងកម្លាំងឥស្សរិយយសរបស់ស្វាមីបានដែរ នេះបញ្ជាក់ឱ្យឃើញកម្លាំងឥស្សរិយៈដែលស្វាមីត្រូវគ្រប់គ្រងភរិយា មិនចង់



និយាយថា ស្វាមីគ្រប់គ្នាត្រូវតែធ្វើជាអ្នកធំក្នុងនគរនោះទេ គឺគ្រាន់តែលើកឡើងនូវភាពសំខាន់មួយដែលនាងជាភរិយាមានចំណូលចិត្តត្រូវការចង់បានប៉ុណ្ណោះ ។ ដូច្នេះ ស្វាមីត្រូវតែប្រគល់នូវភាពជាធំក្នុងការងារផ្ទះ មានការចាត់ចែងម្ហូបអាហារជាដើមឱ្យដល់ភរិយា ចំណែកខ្លួនឯងខំខ្នីឃ្នាតធ្វើការងាររកប្រាក់ ឬទ្រព្យសម្បត្តិទុកដាក់ឱ្យភរិយាជាអ្នករក្សា មិនមែនថាមិនជួយគ្នាទេ គឺត្រូវជួយគ្នាណាស់ ប៉ុន្តែម្នាក់ៗត្រូវប្រាកដច្បាស់តាមតួនាទីរបស់ខ្លួន ។



## តួនាទីស្វាមី

**សិក្ខាបទទី៥ :** ស្វាមីគប្បីសិក្សាថា អាត្មាអញត្រូវឱ្យនូវគ្រឿងប្រដាប់កាយសម្រាប់តែងខ្លួនដល់ភរិយា ។

ជាធម្មតាស្ត្រីរមែងត្រូវការអលង្ការ ទោះបីតិចច្រើនយ៉ាងណាក៏ទៅតាមកម្លាំងទ្រព្យ ដូច្នេះ ស្វាមីគប្បីបំពេញចិត្តភរិយា ត្រង់ចំណុចនេះហាក់ដូចជាមិនចាំបាច់ប្រាប់សោះ ព្រោះថាបើបុរសស្រឡាញ់ស្ត្រីណាហើយក៏តែងប្រាថ្នាឱ្យអលង្ការដល់ស្ត្រីនោះ ណាមួយនាងជាភរិយាទៀតផង ពិតមែនតែភរិយាប្រដាប់អលង្ការប៉ុន្តែវាសង្ហាស្វាមីឯណោះទេតើ ។

តាមពិត ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងអំពីវត្ថុសម្រាប់សង្គ្រោះគ្រប់យ៉ាង ដើម្បីបណ្តុះនូវពូជមេត្រីភាពឱ្យដល់សត្វលោក ដែលសត្វលោកកំពុងតែខ្វល់ខ្វាយក្នុងការស្រឡាញ់ស្អប់គាប់ទាស់ជារៀងរាល់ថ្ងៃមកនោះ ។ អលង្ការជាគ្រឿងលំអកាយពិតមែន ដូច្នេះហើយ ទើបអលង្ការនេះត្រូវបានជាតំណាងឱ្យមេត្តាចិត្ត តំណាងឱ្យសេចក្តីថ្លៃថ្នូរ តំណាងឱ្យសេចក្តីស្មោះត្រង់ ។ល។ បដិសេធការមើលងាយមើលថោក ការវាយដំទាត់ធាក់ និង អំពើអាក្រក់ផ្សេងៗទៀត ដែលជាលាមកមិនមែនអលង្ការ ។



# ត្បូងនាគីភរិយា ៥សិក្ខាបទ

## ត្បូងនាគីភរិយា

**សិក្ខាបទទី១** : ភរិយាគប្បីសិក្សាថា អាត្មាអញត្រូវចាត់ចែងការងារឱ្យបានល្អ ។

ភរិយាត្រូវតម្កល់ខ្លួនឱ្យប្រពៃ ចាត់ចែងការងារឱ្យដល់ស្វាមីដោយសេចក្តីមិនខ្ជិលខ្ជា ទុកស្មើដូចម្តាយ ឬប្អូនស្រី ពុំនោះសោតទេ ត្រូវទុកស្មើជាមិត្រសម្លាញ់ជាមួយនឹងស្វាមីរបស់ខ្លួន ហើយបើទុកដាក់ខ្លួនដល់ទៅថ្នាក់ស្មើដូចទាសីបំរើម្ចាស់ ក៏វាគ្មានថោកទាបអ្វីឡើយ នេះគឺពោលចំពោះការចាត់ចែងក្នុងកិច្ចការងារនៃភរិយាល្អ ដែលជាភរិយាស្រឡាញ់ការងារ ។

ពាក្យថា **ប្រពន្ធ** ប្រែថា ចំណងរួតរឹត ដូច្នេះ

ប្រពន្ធ គឺជាស្ត្រីម្នាក់ដែលចងប្តីដោយចរិយាមារយាទល្អ សណ្តាប់ធ្នាប់សីលធម៌ ឈ្លាសវៃ ស្មោះត្រង់ និង ចាត់ចែងការងារក្នុងផ្ទះដោយប្រពៃ ។

កុំខ្ជិល កុំទម្រន់ ព្រោះការខ្ជិលជាប្រធាននៃសេចក្តីវិនាស បើធ្វើរឿយៗរាល់ថ្ងៃទៅជាទម្លាប់ដ៏ល្អ ការងារសព្វគ្រប់ បីដូចជាអលង្ការ ដូច្នេះ ឱ្យតែការងារប្រាសចាកទោស ធ្វើទៅទោះច្រើនយ៉ាងណា ត្រូវគិតថា ជាសិរីសួស្តី បានកើតមកជាស្រីហើយមានប្តី ត្រូវតែជាភរិយាល្អឱ្យខាងតែបាន ។



# តួនាទីភរិយា

**សិក្ខាបទទី២ :** ភរិយាគប្បីសិក្សាថា អាត្មាអញត្រូវសង្គ្រោះជនជាញាតិទាំងពីរខាង គឺទាំងខាងស្វាមី ទាំងខាងខ្លួនឯងដោយល្អ ។

តែងបានឮរឿយៗនូវពាក្យនេះថា « *មានប្រាក់គឺមានអ្វីៗទាំងអស់* » រួមទាំងគ្រោះថ្នាក់ ទាំងការចង្អៀតចង្អល់ ព្រោះគេសុំ គេខ្ចី និង ទាំងអ្នកដទៃច្រណែនផងមែនទេ ? ប៉ុន្តែបើពោលឱ្យត្រូវជាងហ្នឹង គួរពោលថា « *មានបុណ្យគឺមានអ្វីៗទាំងអស់* » ។

មនុស្សយើងមិនអាចមាននូវសេចក្តីសុខគ្រប់



យ៉ាង ដោយគ្រាន់តែមានប្រាក់នោះទេ វាត្រូវអាស្រ័យប្រាជ្ញាប្រើប្រាស់ចាត់ចែងនូវប្រាក់នោះឱ្យបានល្អជាការដ៏សំខាន់ ជៀសវាងការចាត់ចែងទៅក្នុងការងារដែលមានទោស ជាពិសេសចងមិត្តឱ្យបានច្រើនដោយការបរិច្ចាគសង្គ្រោះ ព្រោះជីវិតមានតម្លៃអាស្រ័យអ្នកដទៃរាប់-អានពេញចិត្ត ប៉ុន្តែបើខ្វះការរាប់អានស្រឡាញ់ពេញចិត្តអំពីអ្នកដទៃ ទោះបីយើងជាសេដ្ឋីក៏ដោយ វាដូចជាចំណីក្រៀមក្រោះដែលខ្សោះរសជាតិអឺចឹងឯង ជីវិតពិតជាគ្មានតម្លៃ អ្នកដទៃញាតិមិត្តគេចាត់ថាយើងស្លាប់បាត់ទៅហើយ ព្រោះយើងខ្វះការសង្គ្រោះញាតិ ។

## តួនាទីភរិយា

**សិក្ខាបទទី៣** : ភរិយាគប្បីសិក្សាថា អាត្មាអញមិនត្រូវប្រព្រឹត្តក្បត់ចិត្តស្វាមីឡើយ ។

ចិត្តមនុស្សមិនងាយមើលធ្លុះ សាំញ៉ាំស្រកេកស្រកាក ចិត្តសត្វតិរច្ឆានងាយសង្កេតឱ្យដឹងជាង ។ ភរិយាស្វាមីមានក្តីស្នេហា បានយល់ចិត្តគ្នាហើយព្រមរៀបការ រហូតមានបុត្រមានទាំងធីតា តែនៅក្បត់គ្នាអាពាហ៍ពិពាហ៍អស់ខ្យល់ ។ នៅថ្ងៃរៀបការហៅអស់ញាតិមិត្ត បងប្អូនឆ្ងាយជិតស្កាត់មកមិនសល់ ធ្វើខ្លួនស្អាតបាតដើម្បីមង្គល ម៉ែឪរវល់បួនប្រាំសប្តាហ៍ ។ ម៉ែឪចងដៃមហាឱ្យពរ ព្រះសង្ឃសូត្រធម៌ អញ្ជើញទេវតា



អញ្ជើញព្រះឥន្ទព្រះព្រហ្មផងណា ក្លាយជាឥតការព្រោះចិត្តមិនស្មោះ ។

ចិត្តស្មោះត្រង់នាំមកនូវកិត្តិយស ការសរសើរលើកតម្កើងអំពីអ្នកផងទាំងពួង ដូច្នេះ មានតែការតាំងចិត្តម៉ឺងម៉ាត់របស់ខ្លួននេះឯង ដែលអាចទទួលយកបាននូវមង្គលល្អប្រាកដប្រជាស័ក្តិសិទ្ធិជាងពរទេវតាឥន្ទព្រហ្មទៅទៀត ។ ដើម្បីឱ្យបានត្រាស់ជាព្រះពុទ្ធ ព្រះបរមពោធិសត្វត្រូវមាននូវអធិដ្ឋានបារមី គឺការតាំងព្រះទ័យមាំក្នុងការងារ មិនមែនបានត្រាស់ដោយសារការឱ្យពរជ័យពីអ្នកដទៃនោះឡើយ ធ្វើជាមនុស្សត្រូវជឿលើការតាំងចិត្តរបស់ខ្លួនជាសំខាន់ ។

៙៙✧៚៚



## តួនាទីភរិយា

**សិក្ខាបទទី៤** : ភរិយាគប្បីសិក្សាថា អាត្មាអញត្រូវថែទាំទ្រព្យសម្បត្តិដែលស្វាមីរកបានមក ។

មិនមែនមិនឱ្យចាយទេប្រាក់នោះ ប៉ុន្តែចាយឱ្យមានរបៀប ដាច់ខាតកុំលេងល្បែងស៊ីសងមានបៀជាដើមឱ្យសោះ កុំឱ្យមានចិត្តលួចលាក់ទុកប្រាក់ប៉ុណ្ណេះប៉ុណ្ណោះ នាំឱ្យមានឈ្មោះថាភរិយាជាចោរ ត្រូវការប្រើ-ប្រាស់ចាត់ចែងធំដុំ ត្រូវជំនុំជាមួយស្វាមី និង ម្យ៉ាងទៀតកុំចង់ហ៊ឺហាដោយសម្ភារៈហួសសមត្ថភាព ឬ ហួសប្រាក់ចំណូល ត្រូវរស់នៅឱ្យស្វាមីទុកចិត្ត ។

ស្វាមីមានកម្លាំងចិត្តធ្វើការដ៏ក្រៃលែង បើ

ទ្រព្យសម្បត្តិនៅផ្ទះគង់វង្ស ព្រោះនាងជាភរិយាមានមារយាទចេះទុកដាក់ថែទាំដោយប្រពៃ ។ ភរិយាជានារីថ្លៃមានពាក្យសម្ដីស្រទន់ពីរោះ ប្រកបដោយទឹកមុខស្រស់បស់ ទទួលស្វាមីមកពីធ្វើការ ។ល។ រឿងកម្លាំងចិត្តពិតជាពិសេសជាងកម្លាំងកាយ ដូច្នេះ សូមភរិយារៀបចំនូវកម្លាំងទាំងពីរឱ្យដល់ស្វាមី កុំធ្វេសប្រហែសផ្នែកខាងកម្លាំងចិត្តឱ្យសោះ ត្រូវព្យាយាមជានិច្ចរាល់ថ្ងៃឱ្យទៅជាទម្លាប់ លទ្ធផលជាទីគាប់ចិត្តវាត្រូវបានមកខ្លួនឯងជាភរិយាហ្នឹងហើយ ។



# គួនារីភរិយា

**សិក្ខាបទទី៩** : ភរិយាគប្បីសិក្សាថា អាត្មាអញត្រូវតែជាស្ត្រីឆ្លាតឈ្លាសមិនខ្ជិលច្រអូស ក្នុងកិច្ចការទាំងពួង ។

ភរិយាគប្បីពិចារណាខ្លួនឯងឱ្យបានរឿយ ៗថា កិច្ចការមេផ្ទះអាត្មាអញបានបំពេញល្អដែរទេ មានសេចក្ដីខ្ជិលមកច្របូកច្របល់ដែរឬអត់ទេ បើឃើញថា ខ្វះខាតគួរបំពេញ បើច្បាស់លាស់ពេញលេញល្អហើយក៏រក្សាឱ្យល្អតទៅ ការងារឆ្លាតវៃជាមង្គលដ៏ឧត្តម ។

សម្ដីអាក្រក់លាមករបស់អ្នកដទៃ គឺទុកត្រឹមអ្នកដទៃចុះ កុំស្រវាប្រមូលមកឱ្យប្រឡាក់ដល់ខ្លួនឯង



ទោះជាអំពើដោយកាយក៏ដោយ ត្រង់អ្នកដទៃធ្វើឬមិនធ្វើជាកិច្ចការងាររបស់គេ បើថាជាកូនចៅក៏អប់រំទូន្មានប្រដៅទៅ ប៉ុន្តែចំពោះខ្លួនឯងវិញត្រូវតាំងស្មារតីកសាងស្នាដៃ កុំភ័យក្រែងល្អលើសគេពេកនោះ ពេលរស់នៅមិនយូរប៉ុន្មានឡើយ ឱកាសសាងល្អមានតិចតួចណាស់ ។

ឈ្នះសេចក្ដីល្ងង់របស់ខ្លួនឯងបាន ដោយការសិក្សាស្វែងយល់ ឈ្នះសេចក្ដីខ្ជិលបាន ដោយការព្យាយាម ឈ្នះសេចក្ដីក្រោធបាន ដោយការមិនក្រោធ ឈ្នះសេចក្ដីអាក្រក់ដោយការធ្វើអំពើល្អ ឈ្នះសេចក្ដីកំណាញ់ដោយការឱ្យទាន ឈ្នះការនិយាយឡេះឡោះដោយពាក្យបានការ ។

# តួនាទីមិត្តល្អ ៥សិក្ខាបទ

## តួនាទីមិត្តល្អ

**សិក្ខាបទទី១ :** មិត្តល្អគប្បីសិក្សាថា អាត្មាអញត្រូវធ្វើទាន គឺឱ្យនូវអ្វីៗដែលគួរឱ្យដល់មិត្តសម្លាញ់ ។

បុគ្គលដែលលះបង់នូវសម្បត្តិទ្រព្យទំនុកបម្រុងអ្នកដទៃ ហ៊ានបែងចែកសេចក្ដីសុខសប្បាយផ្លូវកាយដល់អ្នកដទៃបាន រមែងបានទទួលនូវការលើកតម្កើងរាប់អានអំពីបុគ្គលទូទៅច្រើនប៉ុនណា បុគ្គលដែលបង្កនូវសេចក្ដីទុក្ខលំបាកឱ្យអ្នកដទៃ ដើម្បីប្រយោជន៍សុខផ្ទាល់ខ្លួនឯង ក៏រមែងបានទទួលនូវការតិះដៀល និង ការរង្កៀសចិត្តអំពីអ្នកដទៃទូទៅច្រើនប៉ុណ្ណោះដូចគ្នាដែរ ។



ចំពោះសត្វលោក ពិតមែនតែមិនអាចជ្រើសរើសកំណើតឱ្យខ្លួនឯងបាន ប៉ុន្តែឥឡូវបានកើតមកជាមនុស្សហើយ យើងអាចជ្រើសរើសនូវផ្លូវសម្រាប់ដើរឱ្យខ្លួនឯងបាន គឺគេចជៀសវាងពីផ្លូវមានបន្លា ផ្លូវចោរ ផ្លូវសត្វសាហាវ ពោលគឺផ្លូវអកុសល មករកផ្លូវកុសល ដែលជាផ្លូវស្អាត ផ្លូវគ្មានភ័យអំពីអ្វីៗ ជាផ្លូវនាំឱ្យបានដល់ទីបំផុតទុក្ខ ។

សង្គហទាន គឺជាការសង្គ្រោះមួយដ៏ប្រសើរក្រៃលែង ជាស្បៀងក្នុងការដើរផ្លូវឆ្ងាយ ។

ឲឲ✧ឲឲ

# តួនាទីមិត្តល្អ

**សិក្ខាបទទី២ :** មិត្តល្អគប្បីសិក្សាថា អាត្មាអញត្រូវនិយាយពីរោះមិនទ្រគោះគំរោះគំរើយទៅរកមិត្តសម្លាញ់ឡើយ ។

សេចក្តីចម្រើនយ៉ាងពិតប្រាកដក្នុងជីវិតមនុស្សយើង គឺសេចក្តីចម្រើនផ្នែកកុសលធម៌ អ្នកចម្រើនដោយគុណធម៌ ឈ្មោះថាជាអ្នកទំនុកបម្រុងព្រះសាសនា ធ្វើសាសនាឱ្យចម្រើនលូតលាស់ក្នុងសន្តានចិត្តរបស់ខ្លួន ។

សេចក្តីចម្រើននៃព្រះពុទ្ធសាសនា ដែលពិតប្រាកដ ក៏គឺសេចក្តីចម្រើនផ្លូវចិត្តនៃពុទ្ធបរិស័ទហ្នឹងឯង ចិត្តរបស់ពុទ្ធបរិស័ទដែលនឹងចម្រើនរុងរឿងទៅបាននោះ



ក៏ត្រូវអាស្រ័យព្រះធម៌ក្នុងសាសនា ជាគ្រឿងចិញ្ចឹមបីបាច់រក្សាជានិច្ចកាលដែរ ដូចទារកតូចអាស្រ័យទឹកដោះម្តាយអ៊ីចឹងឯង គឺថាបើយើងយកសីលធម៌នៃព្រះពុទ្ធសាសនាមកជាអាហារ ជាគ្រឿងបីបាច់ថែរក្សាខ្លួន ចិត្តមនុស្សយើងក៏នឹងចម្រើនទៅដោយសេចក្តីស្អាត ចម្រើនដោយពន្លឺភ្លឺស្វាង និង ចម្រើនដោយសេចក្តីស្ងប់ ។

វាចាដែលពីរោះគួរដល់ការសង្គ្រោះមិត្ត គឺជាវាចារបស់អ្នកដែលមានចិត្តស្អាត ចិត្តភ្លឺស្វាង ចិត្តស្ងប់ ។

៙៙✧៙៙



# តួនាទីមិត្តល្អ

**សិក្ខាបទទី៣ :** មិត្តល្អគប្បីសិក្សាថា អាត្មាអញត្រូវប្រព្រឹត្តឱ្យជាប្រយោជន៍ដល់មិត្តសម្លាញ់ ។

ការមិនបៀតបៀនគ្នា គឺជាការមិនបៀតបៀនទាំងខ្លួនឯងទាំងអ្នកដទៃ ជាហេតុនៃសេចក្តីសុខ ចំណែកការបៀតបៀនគ្នាជាហេតុនៃការភ័យខ្លាច មិនស្ងប់ក្នុងជីវិត ព្រោះអាស្រ័យសេចក្តីនេះ បុគ្គលអ្នកប្រាថ្នាឱ្យការរស់នៅមានសេចក្តីប្រសើរ ត្រូវកុំធ្វើនូវអំពើបៀតបៀនផ្សេងៗ ព្យាយាមរក្សាខ្លួនដោយស្មារតី ត្រេកអរក្នុងសេចក្តីមិនប្រមាទ ។

ការបៀតបៀនខ្លួនឯងដោយប្រព្រឹត្តអបាយ-

មុខ ដូចជាការលេងស្រី បរិភោគទឹកស្រវឹង ប្រព្រឹត្តល្បែងស៊ីសង និង ខ្ជិលជាដើម ទោះជាមិនបានបៀតបៀនអ្នកដទៃដោយត្រង់ចំពោះក៏ដោយ តែវាជាការបៀតបៀនដោយអមឬដោយប្រយោល ដូចជាការធ្វើឱ្យទន់ខ្សោយស្មារតី សង្គមមិនចម្រើនលូតលាស់ បញ្ចុះតម្លៃវង្សត្រកូលក្រុមគ្រួសាររបស់ខ្លួន មានការវិវាទគ្នាញឹកញាប់ក្នុងផ្ទះរវាងប្ដីប្រពន្ធជាដើម ស្រែកឡូឡារំខានអ្នកជិតខាង ព្រោះហេតុដូច្នេះ ដើម្បីឱ្យបានជាមនុស្សល្អ មិត្តល្អ ត្រូវប្រព្រឹត្តអំពើជាប្រយោជន៍ដែលផ្ទុយអំពីការបៀតបៀន នេះជាមង្គលដ៏ឧត្តម ។



## តួនាទីមិត្តល្អ

**សិក្ខាបទទី៨** : មិត្តល្អគប្បីសិក្សាថា អាត្មាអញត្រូវសង្គ្រោះមិត្តសម្លាញ់ដោយមិនលើកតម្កើងខ្លួន គឺត្រូវធ្វើជាមនុស្សស្មើប្រកបដោយចរិយាថ្លៃថ្នូរ ។

ជីវិតសព្វថ្ងៃមានសេចក្ដីដឹងខ្លួន ដឹងអារម្មណ៍ ដឹងរឿង គឺជានាទីនៃសភាវធម៌ពិតម្យ៉ាង បានដល់វិថីចិត្តដែលប្រព្រឹត្តតគ្នាមិនដាច់ ពាក្យថាប្រព្រឹត្តតគ្នាមិនដាច់ គឺវិថីចិត្តតាមទ្វារណាមួយក្នុងទ្វារ៦កើតឡើងហើយរលត់ទៅ វិថីចិត្តក្នុងទ្វារដទៃកើតឡើងជាថ្មីបន្តអំពីវិថីចិត្តមុន មានការកើតរលត់បន្តគ្នារហូត ។

វិថីចិត្តកើតរលត់តាមទ្វារ៦ គឺទ្វារភ្នែក ទ្វារ



ត្រចៀក ទ្វារច្រមុះ ទ្វារអណ្ដាត ទ្វារកាយ និង ទ្វារចិត្ត ក្រៅសៃនៃវិថីចិត្ត ជាជីវិតរបស់សត្វលោកដែលរស់នៅក្នុងលោក គឺរូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ និង ធម្មារម្មណ៍ ជាលោកនៃការរស់នៅ ។

ជាពុទ្ធបរិស័ទត្រូវដឹងថាអ្វីជាជីវិត អ្វីជាលោកនៃការរស់នៅ ជីវិតមិនទៀងយ៉ាងណា លោកបែកធ្លាយយ៉ាងម៉េច ដូច្នេះ ទើបរំលត់ ឬ កាត់បន្ថយនូវការប្រកាន់បាន ជាទីរាប់អាននៃមិត្តសម្លាញ់ ព្រោះជាអ្នកមិនប្រកាន់ខ្លួន ។

## គួនាទីមិត្តល្អ

**សិក្ខាបទទី៩** : មិត្តល្អគប្បីសិក្សាថា អាត្មាអញមិនត្រូវបោកបញ្ឆោតដោយការនិយាយកុហក ឱ្យខុសអំពីសេចក្តីពិត ដល់មិត្តសម្លាញ់ឡើយ ។

វាចាមានបីយ៉ាងគឺៈ វាចាលាមក១ វាចាផ្កា១ និង វាចាទឹកឃ្មុំ១ ។ វាចាលាមក បានដល់ការនិយាយកុហក , វាចាផ្កា បានដល់ការមិននិយាយកុហក , វាចាទឹកឃ្មុំ បានដល់ការនិយាយពាក្យពីរោះ ហើយមានប្រយោជន៍ ដូច្នេះ មនុស្សល្អគប្បីសិក្សាថា អាត្មាអញមិនពោលពាក្យកុហកឡើយ ។

មនុស្សនិយាយកុហកជាអ្នកខ្វះគុណធមិច្រើន



ណាស់ ជាបុថុជ្ជនថ្នាក់អន់ ឈើអណ្តែតទឹកប្រសើរជាងមនុស្សនិយាយកុហក ប្រសើរជាងមនុស្សគ្មានគុណធមិទាំងឡាយ ។

មនុស្សយើងថ្លៃថ្នូរដោយគុណធមិ ដោយចរិយាសម្បត្តិ ឫកពាររម្យទម ស្លៀកពាក់សមរម្យ ពាក្យសម្តីត្រឹមត្រូវមិនជ្រាយពេកមិនរឹងពេក មានអត្ថន័យខ្លឹមសារសមគួរដល់អ្នកស្តាប់ ប្រយ័ត្នមាត់រាល់ពេលនិយាយ មានពេលត្រូវនិយាយក៏និយាយតែពាក្យពិត ពាក្យមានប្រយោជន៍ ពាក្យពីរោះ និង និយាយដោយចិត្តសប្បុរស បើស្ងៀមត្រូវស្ងៀមដោយចិត្តស្ងប់ ។



# គួនាទីមិត្តមានឧបការៈ
# ៥សិក្ខាបទ

## តួនាទីមិត្តមានឧបការៈ

**សិក្ខាបទទី១ :** មិត្តមានឧបការៈគប្បីសិក្សាថា អាត្មាអញត្រូវរក្សាមិត្តដែលធ្វេសប្រហែស ។

មនុស្សយើងមានសេចក្តីប្រមាទ ពោលគឺការបាត់បង់នូវសតិជារឿយៗ យ៉ាងនេះហើយ នៅពេលបានបរិភោគទឹកស្រវឹង បន្ថែមឱ្យខ្លួនឯងដែលមានសតិទន់ខ្សោយស្រាប់ទៅហើយនោះ ឱ្យរឹងរឹតតែខូចស្មារតីក្រៃ-លែងឡើងថែមទៀត ក្នុងការប្រមាទបែបនេះ មិត្តមាននូវឧបការៈរមែងជួយរក្សាការពារ ព្រោះថា បុគ្គលអ្នកប្រមាទមិនអាចរក្សាខ្លួនឯងបានឡើយ ។

លោកសេដ្ឋីពិតជាមាននូវអ្វីដែលអ្នកក្រខ្សត់



មិនមានប្រាកដណាស់ ប៉ុន្តែសេដ្ឋីអាចមិនមាននូវអ្វីដែលមនុស្សទ័លក្រមានជាពិតប្រាកដផងដែរ ដូច្នេះការចងមិត្តមិនត្រូវសំដៅរកតែអ្នកមានទ្រព្យច្រើននោះទេ ការដែលសំខាន់គឺនៅលើគុណធម៌ ។

គុណធម៌ឬចិត្តសប្បុរស មិនមែនជារបស់តាំងលក់នៅតាមផ្សារ ឬ តាមហាងនានានោះឡើយ អ្នកមានមាសប្រាក់ច្រើនប៉ុនណា ក៏មិនអាចទិញគុណធម៌បានដែរ ព្រោះហេតុនេះ មនុស្សល្អក្រៅអំពីរកទ្រព្យ ត្រូវអប់រំចិត្តចម្រើនគុណធម៌ ។



## តួនាទីមិត្តមានឧបការៈ

**សិក្ខាបទទី២ :** មិត្តមានឧបការៈគប្បីសិក្សាថា អាត្មាអញត្រូវជួយថែទាំទ្រព្យសម្បត្តិរបស់មិត្តដែលធ្វេសប្រហែស ។

ការថែរក្សាទ្រព្យសម្បត្តិ វាជាការងារមួយចាំបាច់ ទោះជាត្រូវចំណាយទុនខ្លះក៏ដោយ ព្រោះការគង់វង្សនៃទ្រព្យសម្បត្តិ គឺជាកាំជណ្តើរសម្រាប់ឈានឡើងទៅរកអ្វីមួយដែលខ្លួនឯងត្រូវការចង់បាន ប៉ុន្តែទ្រព្យសម្បត្តិក៏ជាមាត់ជ្រោះដ៏រអិលផងដែរ ព្រោះតែសម្បូរទ្រព្យមនុស្សយើងហ៊ានប្រព្រឹត្តទុច្ចរិតច្រើនប្រការ ស្រវឹងហ៊ឺហាស្រីស្រាភ្លេចងាប់ ។

មនុស្សយើងស្វែងរកទ្រព្យសម្បត្តិ ដើម្បីជាបច្ច័យនៃការរស់នៅ សុខសប្បាយក្នុងក្រុមគ្រួសារ ប៉ុន្តែមានទ្រព្យសម្បត្តិហើយ មិនប្រាកដជាបានសុខនោះទេ ពីព្រោះខ្វះស្មារតីក្នុងការកំណត់ដឹងនូវព្រំដែននៃការប្រើប្រាស់ទ្រព្យសម្បត្តិដែលមាននោះឯង ជាអ្នកស្វែងរកសេចក្តីទុក្ខមកដាក់ខ្លួន និង ក្រុមគ្រួសាររបស់ខ្លួន ជាទាសកម្មករនៃតណ្ហាក្នុងការងារស្វែងរកទ្រព្យ មានទ្រព្យហើយមិនបានសុខដោយសារទ្រព្យនោះឡើយ ជាមនុស្សកំសត់ដ៏អាថិកំបាំង ក្នុងចំណោមមនុស្សក្រលំបាកតោកយ៉ាកទាំងឡាយ ដូច្នេះ មនុស្សល្អគឺជាអ្នកមិនប្រមាទចំពោះទ្រព្យសម្បត្តិ ព្រោះទ្រព្យសម្បត្តិជាអាវុធមុខពីរ មានបញ្ញាទើបបានរួចខ្លួន ។

៙៙✧៚៚



# គួនាទីមិត្តមានឧបការៈ

**សិក្ខាបទទី៣** : មិត្តមានឧបការៈគប្បីសិក្សាថា អាត្មាអញគឺជាទីពឹងពាក់ពំនាក់អាស្រ័យរបស់មិត្តពិតប្រាកដ នៅពេលដែលមិត្តមានភ័យ ។

នៅពេលមិត្តមានវិបត្តិ ភ័យព្រួយអំពីរឿងអ្វីមួយ មិត្តដែលមាននូវឧបការៈបានពោលដូច្នេះថា « *មិត្តឯងកុំភ័យកុំព្រួយអ្វីឡើយ កាលបើសម្លាញ់ដូចជារូបខ្ញុំនៅរស់ មិត្តឯងកុំខ្លាចឱ្យសោះ* » ហើយក៏ជួយដោះស្រាយកម្ចាត់បង់នូវភយន្តរាយនោះៗ បានពិតប្រាកដ ដូចមាត់ថាមែន ។

សត្វលោកដែលកើតមកហើយ សុទ្ធសឹងតែ



ត្រូវការនូវសេចក្តីសុខ ដូច្នេះ បើយើងមិនបានជួយទំនុកបម្រុងគេទេ កុំតែបៀតបៀនគេដើម្បីសេចក្តីសប្បាយរបស់ខ្លួន និង ក្រុមគ្រួសាររបស់ខ្លួនទៅក៏គង់នៅក្នុងគ្រាន់ បានកើតមកជាមនុស្សហើយ ត្រូវខំប្រឹងសាងនូវសមត្ថភាព ចិញ្ចឹមជីវិតដោយបរិសុទ្ធិ រួចផុតអំពីការទៅបៀតបៀនអ្នកដទៃដើម្បីតែជីវិតខ្លួនឯង ។

មនុស្សខ្លះមានលាភមានយសខ្ពង់ខ្ពស់មុខមាត់សប្បាយចិត្តណាស់ ប៉ុន្តែតាមពិតអន់បំផុត ព្រោះគ្មានសមត្ថភាពចិញ្ចឹមជីវិតខ្លួនឯងបានឡើយ គឺទាល់តែធ្វើចោរ ... ទើបអាចរស់នឹងគេកើត តើចង់រស់របៀបនេះដើម្បីអ្វី ? តម្លៃជីវិតនៅត្រង់ណា ?

៙៙✧៚៚

## គុណនាទីមិត្តមានឧបការៈ

**សិក្ខាបទទី៤** : មិត្តមានឧបការៈគប្បីសិក្សាថា អាត្មាអញមិនត្រូវបោះបង់ចោលមិត្តក្នុងគ្រាមានវិបត្តិ ។

នៅពេលមិត្តមានភ័យ ឬវិបត្តិធំតូចអ្វីមួយនោះ មិត្តមានឧបការៈរួមសុខទុក្ខ មិនបោះបង់ចោលឡើយ គឺនៅរាប់អានជាមិត្ត នៅជិតដិតជួយលើកស្ទួយគ្នា នៅជាទីពឹងបីដូចជាអាវធំក្រាស់ក្នុងរដូវរងា ។

មិត្តល្អកម្ររកបាន ផ្ទុយមកវិញ មានមិត្តខ្លះព្រោះហេតុតែមាសប្រាក់កិត្តិយស និង ការសរសើរ ហ៊ានលះបង់ញាតិមិត្ត ម៉ែឪបងប្អូន ម្យ៉ាងទៀត ព្រោះ



លោភក្នុងសម្បត្តិទ្រព្យ មិត្តក្លាយជាសត្រូវ ឬទៅជាចោរលួចប្លន់សម្បត្តិទ្រព្យអ្នកស្រុកអ្នកនគរ លួចទ្រព្យសម្បត្តិជាតិ សម្បត្តិរួម ដែលសម្បត្តិទ្រព្យនោះមានទាំងទាសកម្មករ និង អ្នកសុំទានជាម្ចាស់ផងដែរ អ្នកលួចសម្បត្តិជាតិ ជាមនុស្សថោកថយជាងអ្នកសុំទានទៅទៀត ដូច្នេះមនុស្សចោរមិនមែនជាមិត្តល្អឡើយ ។

ដើម្បីឱ្យបានជាមិត្តល្អរបស់ប្រជាពលរដ្ឋ ត្រូវចេះដាស់តឿនខ្លួនដោយខ្លួនឯង ធ្វើជាតម្រួតម្នាក់ត្រួតខ្លួនឯង ដោយកុំចាំបាច់ទាល់តែគេត្រួត កាលបើយ៉ាងនេះឈ្មោះថា គ្រប់គ្រងខ្លួនឯងបាន ។



## គុណនាទីមិត្តមានឧបការៈ

**សិក្ខាបទទី៥** : មិត្តមានឧបការៈគប្បីសិក្សាថា អាត្មាអញត្រូវរាប់អានរហូតដល់ផៅពង្សរបស់មិត្ត ។

មិត្តល្អនាំយើងទៅរកសេចក្តីចម្រើន ជួយហាមឃាត់យើងកុំឱ្យប្រព្រឹត្តធ្វើនូវអំពើអាក្រក់ ប្រៀបដូច ជួយឃាត់ផ្លូវកុំឱ្យទៅតំបន់ខ្លាំង ដូច្នោះឯង ម្យ៉ាងទៀត មិត្តល្អបានដឹកនាំយើងក្នុងផ្លូវមានប្រយោជន៏ ឱ្យយើងដើរទៅរកព្រះធម៌ ធ្វើឱ្យយើងស្គាល់ព្រះធម៌ និងជ្រះថ្លាក្នុងការទទួលយកព្រះធម៌មកទុកក្នុងខ្លួន សម្រាប់ធ្វើការបូជាគឺបដិបត្តិតាម ព្រះធម៌ជាកំពូលមិត្តក្នុង

ដំណើរជីវិតវែងឆ្ងាយ ជាគ្រឿងកក់ក្ដៅដ៏ក្រៃលែងយ៉ាងនេះហើយ ទើបយើងគួររាប់អានដល់ទៅផៅពង្សក្រុមគ្រួសាររបស់មិត្តល្អ ។

មានមនុស្សច្រើនគួរសមដែរ ដែលចេះជក់បារីបរិភោគទឹកស្រវឹង និង អបាយមុខផ្សេងៗទៀត ដោយសារមិត្រភក្ដិ រហូតដល់ពោលថា ឈប់ប្រព្រឹត្តមិនបានព្រោះខ្លាចមិត្រភក្ដិលែងរាប់អាន សុំសួរថា ក្នុងលោកនេះគេចងមិត្តដើម្បីអ្វី ? សូមពន្យល់អត្ថន័យអំពីការស្វែងរកមិត្ត តើមិត្តដែលអូសកយើងទម្លាក់ជ្រោះ ជាមិត្តប្រភេទណា? ចំណែកមិត្តល្អនាំមកនូវសេចក្ដីសុខចម្រើនដូចម្ដេចក៏ចេះចោលបាន ?

៙៙✧༄༄



# តួនាទីចៅហ្វាយនាយ
# ៥សិក្ខាបទ

## តួនាទីចៅហ្វាយនាយ

**សិក្ខាបទទី១** : ចៅហ្វាយនាយគប្បីសិក្សាថា អាត្មាអញត្រូវចាត់ចែងការងារឱ្យសមគួរតាមកម្លាំងរបស់ទាសៈ និង កម្មករ ។

មេត្តាករុណាព្រមដោយបញ្ញា ជាគុណធម៌សំខាន់ណាស់សម្រាប់ចៅហ្វាយនាយប្រព្រឹត្តទៅលើទាស និង កម្មករ ចៅហ្វាយនាយមានកេរ្តិ៍ឈ្មោះល្អដោយសារទាសៈ និង កម្មករស្រឡាញ់ចូលចិត្ត អ្វីៗដែលគេនិយមចូលចិត្តរាប់អានច្រើនៗ ជារបស់មានតម្លៃ ។

មនុស្សយើងត្រូវរស់នៅដើម្បីឱ្យអ្នកដទៃបានសប្បាយចិត្ត មានអ្វីដែលយើងអាចជួយឱ្យអ្នកដទៃ

សប្បាយចិត្តបាន យើងគួរជួយនូវអ្វីនោះទៅ ព្រោះការជួយឱ្យអ្នកដទៃសប្បាយចិត្តនោះ ក៏គឺជាការជួយឱ្យខ្លួនឯងបានសប្បាយរីករាយត្រជាក់ចិត្តព្រមគ្នាផងដែរ ។

ការសប្បាយចិត្ត ជាចំណុចសំខាន់របស់មនុស្សគ្រប់គ្នា ជាបេះដូងនៃសុភមង្គល ជាខ្យល់ដង្ហើមនៃសិរីសួស្តី នេះពោលចំពោះការសប្បាយចិត្តណាដែលប្រាស-ចាកទោសប៉ុណ្ណោះ ការសប្បាយចិត្តនេះជាកំណប់មហាសាល ជាទិសដៅនៃអ្នកប្រព្រឹត្តធម៌ទៅតាមឱវាទរបស់ព្រះសម្មាសម្ពុទ្ធជាបរមសាស្តា ការសប្បាយចិត្តដែលប្រាសចាកទោសព្រោះប្រកបដោយបញ្ញា ។



# តួនាទីចៅហ្វាយនាយ

**សិក្ខាបទទី២** : ចៅហ្វាយនាយគប្បីសិក្សាថា អាត្មាអញត្រូវឱ្យភត្តាហារ និង ថ្លៃឈ្នួលត្រឹមត្រូវដល់ទាសៈ និង កម្មករ ។

ចៅហ្វាយនាយដែលមានទឹកចិត្តអនុគ្រោះដល់ទាសកម្មករ គឺមិនមែនគ្រាន់តែឱ្យទាសៈ និង កម្មករបានរស់នៅសម្រាប់បំរើការងារ ដូចសត្វពាហនៈនោះទេ ជីវិតទាសៈ និង កម្មករក៏មកដោយសារបុណ្យដែរ ព្រោះជាមនុស្ស ដូច្នេះ ចៅហ្វាយនាយត្រូវអនុគ្រោះដល់ទាសៈ និង កម្មករឱ្យបានរស់ផង មានផលកម្រៃផ្សេងទៀតផង មិនមែនត្រឹមតែរស់ សម្រាប់បំរើការឱ្យខ្លួនឯងជាចៅ-



ហ្វាយនាយប៉ុណ្ណឹងទេ សូមកុំទុកដាក់ជីវិតមនុស្សណាម្នាក់ សម្រាប់តែជីវិតខ្លួនឯងដែលជាចៅហ្វាយនាយ ឬជាអ្នកធំឱ្យសោះ ។

យើងជាមនុស្សម្នាក់ ដែលហៅខ្លួនឯងថាជាមនុស្ស ហើយយើងក៏ជាមនុស្សម្នាក់ដែលគេសន្មតថាជាចៅហ្វាយនាយដែរ ដូច្នេះ គុណធម៌របស់មនុស្សក្តី គុណធម៌របស់ចៅហ្វាយនាយក្តី គប្បីតម្កល់ក្នុងសន្តានឱ្យបានល្អ ហើយចាត់ចែងផ្សព្វផ្សាយនូវគុណធម៌នោះ ឱ្យដូចជាម្លប់ឈើក្នុងរដូវក្តៅដូច្នោះឯង ។

# តួនាទីចៅហ្វាយនាយ

**សិក្ខាបទទី៣ :** ចៅហ្វាយនាយគប្បីសិក្សាថា អាត្មាអញត្រូវថៃទាំរក្សា ឱ្យសម្រាកការងារ និង ជួយព្យាបាលនៅពេលទាសៈ និង កម្មករមានជម្ងឺ ។

ដើម្បីជាប្រយោជន៍ និង សេចក្តីសុខសម្រេចបានដល់អ្នកដទៃ យើងត្រូវតែលះបង់នូវសេចក្តីសុខផ្លូវកាយផ្ទាល់ខ្លួន តិច ឬច្រើនតាមតែការពេញចិត្ត ត្រូវចាំទុកថា មនុស្សយើងកើតមកសម្រាប់ជួយដល់សង្គមសត្វមានជីវិត មិនមែនកើតមកសម្រាប់បំផ្លាញ ឬ បៀតបៀនដល់សង្គមតូចធំនោះទេ ព្រោះមនុស្សជាសត្វវិសេសជាងគេ អាចកសាងការចេះដឹងបានច្រើនជា



ទីបំផុត រហូតបានជាព្រះសម្មាសម្ពុទ្ធទៀតផង ។

យើងត្រូវតែជាមនុស្សម្នាក់រីករាយនឹងជួយដល់សង្គមមនុស្សសត្វ ជៀសវាងឱ្យផុតពីការប្រមូលសម្បត្តិទ្រព្យរួមមកបំរើតណ្ហារបស់ខ្លួនឯង មិនកាប់ព្រៃឈើខាងក្រៅដែលជាលំនៅរបស់សត្វ ប៉ុន្តែកាប់ព្រៃឈើខាងក្នុងគឺកិលេសក្នុងសន្តាន រួចហើយដាំនូវដំណាំពោលគឺសន្តោសប្រោសប្រណី ។

សេចក្តីសំគាល់ថា ខ្លួនឯងជាមនុស្សសំខាន់ វាជាហេតុនៃសេចក្តីទុក្ខកង្វល់ច្រើនយ៉ាង តាមពិតក្នុងមនុស្សយើងម្នាក់ៗ មិនផុតអំពីដីទឹកភ្លើងខ្យល់ អាកាសធាតុ និង វិញ្ញាណធាតុឡើយ ។

៙៙✧៚៚



# តួនាទីចៅហ្វាយនាយ

**សិក្ខាបទទី៤ :** ចៅហ្វាយនាយគប្បីសិក្សាថា អាត្មាអញត្រូវចែករំលែកនូវចំណីអាហារ ឬផ្លែឈើណាៗដែលមានរសដ៏ត្រកាលចំឡែកឱ្យដល់ទាសៈ និង កម្មករ ។

អ្នកក្រខំប្រឹងត្រដររស់ បានប្រាក់កម្រៃខ្លះផ្គត់-ផ្គង់គ្រួសារចិញ្ចឹមប្រពន្ធកូន មានខ្លះចិញ្ចឹមមាតាបិតាដែលចាស់ជរាទៀតផង តើមានប្រាក់ឯណាទៅរកចំណីល្អ ផ្លែឈើមានតម្លៃពិសេសត្រកាល មកបរិភោគបាននោះ ដូច្នេះ សូមចៅហ្វាយនាយមេត្តាអនុគ្រោះនូវទាសៈនិង កម្មករ បើមិនបានញឹកញាប់ក៏គង់ម្តងៗតាមសមគួរ

ដើម្បីទាសៈ និង កម្មករមានកម្លាំងចិត្តតស៊ូក្នុងការងារ ។

ចៅហ្វាយនាយចិត្តបុណ្យ មានទ្រព្យធនធានច្រើន ក៏ចាត់ចែងឱ្យមានកិច្ចការងារសម្រាប់មនុស្សច្រើនគ្នាបានធ្វើ ពោលគឺជួយឱ្យមនុស្សមានការងារ មិនគិតកេងប្រវ័ញ្ចកម្លាំងអ្នកដទៃអ្វីឡើយ ទោះបីខ្លួនឯងត្រូវបង់ដើមទុនអស់ច្រើនយ៉ាងណា ហើយបានចំណូលមកវិញពុំស្មើដើមក៏ដោយ ក៏គង់សប្បាយចិត្ត ត្បិតកម្មករបានរស់ដោយសារមានការងារធ្វើ នេះជារបៀបជួយចិញ្ចឹមមនុស្សយ៉ាងល្អប្រសើរបំផុត ។



# តួនាទីចៅហ្វាយនាយ

**សិក្ខាបទទី៥** : ចៅហ្វាយនាយគប្បីសិក្សាថា អាត្មាអញត្រូវឱ្យទាសៈ និង កម្មករ ឈប់សម្រាកអំពីការងារក្នុងសម័យដែលគួរ ។ សម័យដែលគួរមានពីរគឺ :

១-<u>និច្ចសម័យ</u> : ទាសៈ និង កម្មករធ្វើការពេញមួយថ្ងៃរមែងនឿយហត់ខ្លាំង ដូច្នោះ ត្រូវមានពេលសម្រាកកុំឱ្យនឿយហត់បាក់កម្លាំង ។

២-<u>កាលសម័យ</u> : ការឱ្យគ្រឿងតាក់តែងកាយ និង អាហារពិសេសជាដើម ក្នុងថ្ងៃបុណ្យសំខាន់ៗប្រចាំសាសនា ឬ ថ្ងៃបុណ្យប្រពៃណីជាតិ កំណត់ឱ្យ



សម្រាកអំពីការងារ ។

ការជួយប្រទេសជាតិគឺគិតប្រយោជន៍រួម បានសេចក្តីថាជាការជួយមនុស្សច្រើនរាប់លាននាក់ ការជួយគឺការសង្គ្រោះ ការជ្រោមជ្រែង តាមពាក្យសាសនាហៅថាបុណ្យកុសល ដូច្នេះ បើខ្លួនយើងតែម្នាក់សោះទេ ប៉ុន្តែអាចជួយមនុស្សរាប់លាននាក់ឱ្យបានសេចក្តីសុខ យើងគួរគប្បីលះបង់នូវគំនិតដែលគិតតែប្រយោជន៍ផ្ទាល់ខ្លួន , បរិច្ចាគកម្លាំងកាយចិត្តជួយដោយរីករាយទៅចុះ ។

មនុស្សយើងកើតមកដើម្បីជួយគ្នា ព្រោះធម្មជាតិបានរៀបចំនូវសមត្ថភាពឱ្យដល់មនុស្ស បើពុំដូច្នោះ ធម្មជាតិនឹងផ្តន្ទាទោសតាមកំហុសដែលមាន ។

# តួនាទីទាសៈ និង កម្មករ
# ៥សិក្ខាបទ

## តួនាទីទាសៈ និង កម្មករ

**សិក្ខាបទទី១ :** ទាសៈ និង កម្មករគប្បីសិក្សាថា អាត្មាអញត្រូវក្រោកឡើង ធ្វើការងារមុនចៅហ្វាយនាយ ។

ការដេកច្រើនជាប្រធាននៃសេចក្តីវិនាស មិនចំពោះតែមនុស្សណានោះទេ លើកលែងតែអ្នកជម្ងឺដែលត្រូវសម្រាក ។ ពេលវេលាសម្រាប់រស់មានតិចតួចណាស់ ដូច្នេះ មនុស្សល្អត្រូវតែសន្សំសំចៃពេលវេលាធ្វើការងារឱ្យបានច្រើន កុំខ្ជះខ្ជាយពេលវេលាឱ្យសោះ ។

ការងារមិនច្របូកច្របល់ជាឧត្តមមង្គល ពោលគឺមិនច្របូកច្របល់ដោយសេចក្តីខ្ជិល ។



ពេញចិត្តចំពោះកិច្ចការ ឧស្សាហ៍ព្យាយាមយកចិត្តទុកដាក់ចំពោះការងារប្រចាំតួនាទី ឆ្លាតចំពោះហេតុផលដែលនាំឱ្យចម្រើន និង មិនចម្រើន ស្មោះត្រង់ចំពោះចៅហ្វាយនាយ ធ្វើការមិនគិតប្រៀបធៀបនឹងតម្លៃឈ្នួល ទាំងអស់នេះជាកូនសោសម្រាប់ចាក់យកសិរីសួស្តីមកឱ្យខ្លួនឯង ។

ជីវិតកើតមក និង រស់នៅដោយសារការងារទៅហើយ ម្តេចក៏ចាំបាច់ខ្ជិល ដូច្នេះប្រឹងទៅ តស៊ូទៅយកការងារជាគ្នាជាខ្នើយទៅ មានតែការងារនេះឯងហើយជាព្រះប្រោសជីវិតរបស់យើង សូមឧទ្ទិសជីវិតនេះចំពោះការងារប្រាសចាកទោស រហូតដង្ហើមចុងក្រោយ ។

៙៙✧៚៚

## តួនាទីទាសៈ និង កម្មករ

**សិក្ខាបទទី២ :** ទាសៈ និង កម្មករគប្បីសិក្សាថា អាត្មាអញត្រូវឈប់សម្រាកអំពីការងារក្រោយចៅហ្វាយនាយ ។

កើតមកជាមនុស្ស តែងជួបប្រទះនូវការងារដែលត្រូវធ្វើ ប្រទីបនៃជីវិតដែលសម្រាប់ញ៉ាំងការរស់នៅឱ្យមានពន្លឺរស្មី វាអាស្រ័យនៅលើការងារគោរពតួនាទីរបស់ខ្លួនហ្នឹងឯង ការងារតាមតួនាទីជាអាយុជីវិតរបស់មនុស្ស ជាគ្រឿងអលង្ការសម្រាប់លំអឱ្យជីវិត និងជាមង្គលសិរីសួស្តីនៃជីវិតបុរសស្ត្រីគ្រប់គ្នា ។

មនុស្សជាសត្វដ៏វិសេស មានចំណេះព្រមដោយ



ចិត្តគំនិតប្រសើរឧត្តម អាចសិក្សារៀនសូត្រផ្លូវលោកផ្លូវធម៌ ស្វែងយល់នូវវិជ្ជាផ្សេងៗ និង អាចកសាងខ្លួនតាមដំណើរដែលយល់ដឹង អប់រំទូន្មានចិត្តឱ្យជាមនុស្សពេញលក្ខណៈ ដូច្នេះតួនាទីរបស់មនុស្ស មិនមែនជាឃាតករ មិនមែនជាចោរ មិនមែនជាអ្នកប្រព្រឹត្តអនាចារផ្សេងៗជាដើមឡើយ តួនាទីរបស់មនុស្សគឺសាងគុណសម្បត្តិក្នុងចិត្តកម្ចាត់ទោសក្នុងសន្តាន ធ្វើនូវប្រយោជន៍ក្នុងសង្គមសត្វលោកឱ្យរីកចម្រើនស្រស់ថ្លា រុងរឿងត្រចះត្រចង់ ដូចរុក្ខជាតិក្នុងរដូវភ្លៀង ។

៙៙✧៚៚



## តួនាទីទាសៈ និង កម្មករ

**សិក្ខាបទទី៣ :** ទាសៈ និង កម្មករគប្បីសិក្សាថា អាត្មាអញត្រូវកាន់យកតែរបស់ដែលចៅហ្វាយនាយឱ្យតែប៉ុណ្ណោះ ។

ការងាររំដោះគ្រោះ ជាការងារដែលមនុស្សគ្រប់គ្នាកំពុងតែធ្វើ ទោះជាធ្វើអ្វីក៏ដោយ ឱ្យតែនៅក្នុងរឿងរក្សាជីវិត ការពារទប់ស្កាត់កុំឱ្យជីវិតមានសេចក្តីលំបាក តាំងតែអំពីការសុំទាន ការខំប្រឹងលីសែងក្នុងភាពខ្លួនឯងជាទាសៈឬកម្មករ ការស្លៀកពាក់ហូបចុករបស់មនុស្សគ្រប់គ្នារាល់ថ្ងៃឡើងទៅ ។

គ្រប់គ្នាខំប្រឹងរំដោះគ្រោះ ព្រោះជីវិតកំពុងតែ

មានគ្រោះ ក្នុងបណ្ដាគ្រោះម៉ឺនសែនជំពូក មានគ្រោះដែលសត្វលោកមិនងាយនឹងរំដោះឱ្យរួចគឺ ចាស់ ឈឺ ព្រាត់ប្រាស និង ស្លាប់ មិនត្រឹមតែប៉ុណ្ណោះ ការកើតក្នុងភពថ្មីទៀតជាគ្រោះដ៏កាចសាហាវ ។

គ្រោះដែលកំពុងប្រឈមមុខ និង ជាហេតុនៃគ្រោះផ្សេងៗទៀតសព្វគ្រប់ទាំងអស់នោះ គឺចិត្តបាប ដូច្នេះ ការតាំងចេតនាវៀរចាកបាបទាំងពួង ជាពិធីរំដោះគ្រោះដែលមនុស្សគ្រប់គ្នាត្រូវតែធ្វើ ត្រូវមានជំនឿលើការរំដោះគ្រោះឱ្យខ្លួនឯង ។



# តួនាទីទាសៈ និង កម្មករ

**សិក្ខាបទទី៤** : ទាសៈ និង កម្មករគប្បីសិក្សាថា អាត្មាអញត្រូវធ្វើការងារឱ្យចៅហ្វាយនាយដោយការយកចិត្តទុកដាក់ ពោលគឺធ្វើការងារឱ្យបានល្អ។

បានជាធ្វើហើយ ធ្វើឱ្យល្អតែម្ដងទៅ គឺធ្វើដោយការយកចិត្តទុកដាក់ ជាអ្នកស្រឡាញ់ការងារមិនគិតតែប្រាក់ តស៊ូទ្រាំលំបាកក្នុងកិច្ចការដោយរីករាយតាមផ្លូវចិត្ត ត្បិតគិតឃើញថា អាត្មាអញខ្សត់ទ្រព្យមែន ប៉ុន្តែមានកម្លាំងជួយខ្លួនឯងផង ជួយចៅហ្វាយនាយផង ប្រសើរជាងឈឺលំបាកឥតប្រយោជន៍ ។

ការយកចិត្តទុកដាក់ក្នុងការងារ វាជាអធ្យា-



ស្រ័យនៃមារយាទ អ្នកមានមារយាទល្អ គឺជាអ្នកមាននូវបយោគសម្បត្តិ ដែលជាសម្បត្តិមួយវិសេសសម្រាប់បើកមុខឱ្យបុណ្យផ្ដល់ផល ដូច្នេះ អ្នកមានមារយាទល្អ គឺជាអ្នកមានសិរីសួស្ដីនៅជាមួយ អាចបានជាមេដឹកនាំក្នុងក្រុមក្នុងកង ឬអាចបានជាមនុស្សពិសេស ក្លាយពីទាសៈកម្មករមកជាជំនិតរបស់ចៅហ្វាយនាយ រហូតក្លាយជាកូនប្រសាររបស់ចៅហ្វាយនាយ អាចក្លាយជាសេដ្ឋីក្នុងបច្ចុប្បន្នជាតិ ដូច្នេះ មនុស្សល្អជាអ្នកមិនប្រមាទក្នុងការងារ ។

## តួនាទីទាសៈ និង កម្មករ

**សិក្ខាបទទី៥** : ទាសៈ និង កម្មករគប្បីសិក្សាថា អាត្មាអញត្រូវនាំនូវកិត្តិគុណគឺកេរ្តិ៍ឈ្មោះល្អរបស់ចៅហ្វាយនាយទៅផ្សព្វផ្សាយ ពោលសរសើរក្នុងចំណោមមហាជន ។

នៅពេលយើងពោលសរសើរអ្នកដទៃណាម្នាក់នោះ ត្រូវបញ្ជាក់អំពីចំណុចដែលគួរឱ្យសរសើរនោះផង បើយើងមិនបានបញ្ជាក់អំពីចំណុចល្អឱ្យបានពិតប្រាកដទេ វាអាចធ្វើឱ្យអ្នកស្តាប់យល់ច្រឡំរឿងអាក្រក់ថាជារឿងល្អ ព្រោះមនុស្សយើងម្នាក់ៗដែលនៅមានកិលេសនោះរមែងមានទាំងអំពើល្អមានទាំងអំពើអាក្រក់ ។



ទាសៈនិងកម្មករ អាចពោលសរសើរចៅហ្វាយនាយដោយចិត្តស្មោះ ចំពោះគុណសម្បត្តិ ៥យ៉ាង ណាមួយក៏បាន ដែលចៅហ្វាយនាយមានមកលើខ្លួន និង អ្នកឯទៀតនោះ ការពោលសរសើរដោយចិត្តស្មោះ ព្រោះជ្រះថ្លាក្នុងគុណរបស់ចៅហ្វាយពិតៗ មិនមែនពោលសរសើរព្រោះចង់បានអ្វីៗអំពីចៅហ្វាយទេ ការដឹងគុណ ការតបគុណ ការសរសើរ ជាកិច្ចការតួនាទីរបស់មនុស្សល្អគ្រប់គ្នា ។

វាចាដែលពោលត្រឹមត្រូវ គឺពោលពាក្យពិតហើយមានប្រយោជន៍ ជាមង្គលដ៏ឧត្តម ។



# តួនាទីពុទ្ធបរិស័ទជាគ្រហស្ថ
# ៥សិក្ខាបទ

## តួនាទីពុទ្ធបរិស័ទជាគ្រហស្ថ

**សិក្ខាបទទី១ :** ពុទ្ធបរិស័ទជាគ្រហស្ថ គប្បីសិក្សាថា អាត្មាអញត្រូវមានកាយកម្មប្រកបដោយមេត្តា ។

ពុទ្ធបរិស័ទជាអ្នករាប់អានព្រះរតនត្រ័យ មានព្រះរតនត្រ័យជាទីពឹងទីរលឹក ដូច្នេះ ពុទ្ធបរិស័ទគប្បីនឹករលឹកដល់ព្រះគុណរបស់ព្រះសម្មាសម្ពុទ្ធ ទោះជាព្រះគុណផ្នែកមហាករុណាក្តី ព្រះគុណផ្នែកសេចក្តីបរិសុទ្ធក្តី ព្រះគុណផ្នែកបញ្ញាក្តី ព្រះគុណទាំងបីផ្នែកនេះ សុទ្ធតែប្រមាណពុំបានឡើយ ។

ពុទ្ធបរិស័ទត្រូវនឹករលឹកដល់ព្រះគុណរបស់



ព្រះសម្មាសម្ពុទ្ធជាអង្គម្ចាស់ នឹករឿយៗ រលឹករឿយៗ រហូតទាល់តែព្រះគុណទាំងនោះ មកប្រថាប់នៅក្នុងចិត្តរបស់ខ្លួន នេះគឺពុទ្ធានុស្សតិ ។

ចិត្តនៃពុទ្ធបរិស័ទ រមែងនៅជាមួយព្រះសម្មាសម្ពុទ្ធជានិច្ចកាល មិននៅជាមួយមារ មិននៅជាមួយខ្មោចព្រាយបិសាច ចិត្តពុទ្ធបរិស័ទមិនជាសត្វតិរច្ឆាន មិនជាសត្វនរក មិនជាប្រេត មិនជាអសុរកាយ ចិត្តរបស់ពុទ្ធបរិស័ទរមែងចម្រើនដោយមេត្តាករុណា ចម្រើនដោយសេចក្តីបរិសុទ្ធ និង ចម្រើនដោយបញ្ញា ព្រោះបាននៅនែបនិត្យជិតជាមួយព្រះពុទ្ធជាអង្គម្ចាស់ ។

៙៙✧៚៚



## តួនាទីពុទ្ធបរិស័ទជាគ្រហស្ថ

**សិក្ខាបទទី២ :** ពុទ្ធបរិស័ទជាគ្រហស្ថ គប្បីសិក្សាថា អាត្មាអញត្រូវមានវចីកម្មប្រកបដោយមេត្តា ។

ពុទ្ធបរិស័ទរាប់អានព្រះពុទ្ធ គោរពព្រះពុទ្ធ ក៏រាប់អានព្រះធម៌ គោរពព្រះធម៌ផងដែរ ព្រះធម៌គឺពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ និង មគ្គផលព្រះនិព្វាន ។

រាប់អានព្រះធម៌ គោរពព្រះធម៌ គឺបានដល់ការសិក្សាព្រះធម៌ ស្តាប់ព្រះធម៌ ឬ អានគម្ពីរធម៌រឿយៗ ហើយយកព្រះធម៌ជាកញ្ចក់ឆ្លុះមើលការប្រព្រឹត្តរបស់ខ្លួន

បើកាយកម្ម វចីកម្ម មនោកម្ម មានការសៅហ្មង ប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនឯង និង អ្នកដទៃ ក៏គប្បីលាងជម្រះដោយស្មារតីគោរពព្រះធម៌ បើពិនិត្យមើលទៅឃើញស្អាតល្អហើយ គប្បីនៅដោយការរីករាយជ្រះថ្លាសមាទានក្នុងកុសលធម៌នោះៗទាំងយប់ទាំងថ្ងៃតទៅ ។

បុរសស្ត្រីក្នុងលោក ឆ្លុះកញ្ចក់សម្អាតរូប យ៉ាងណាមិញ ពុទ្ធបរិស័ទក៏យកព្រះធម៌ជាកញ្ចក់សម្រាប់ឆ្លុះសម្អាតចិត្ត សម្អាតកាយវាចា យ៉ាងនោះដែរ ។

ពុទ្ធបរិស័ទយកព្រះធម៌ជាគោលបដិបត្តិនៅក្នុងជីវិតប្រចាំថ្ងៃ ដូចមានដួងប្រទីបបំភ្លឺផ្លូវក្នុងវេលាយប់អឺចឹងឯង ។



# តួនាទីពុទ្ធបរិស័ទជាគ្រហស្ថ

**សិក្ខាបទទី៣ :** ពុទ្ធបរិស័ទជាគ្រហស្ថគប្បីសិក្សាថា អាត្មាអញត្រូវមានមនោកម្មប្រកបដោយមេត្តា ។

ព្រះពុទ្ធសាសនា ជាសាសនាសម្រាប់មនុស្សឆ្លាត សម្រាប់មនុស្សដែលមានចិត្តរឹងប៉ឹង មានសតិជាគ្រឿងរក្សាខ្លួន មានកាយវាចាទន់ភ្លន់ឱនលំទោនគោរពគុណព្រះរតនត្រ័យដោយការឈ្លាសវៃ ប៉ុណ្ណេះជាដើម អ្នករាប់អានព្រះពុទ្ធសាសនាជាអ្នកឆ្លាតយ៉ាងនេះ ទើបបានទទួលផលអំពីការរាប់អានពិតប្រាកដ ជាអ្នកឃើញផលនោះជាក់ច្បាស់ដោយខ្លួនឯង ។



មនុស្សមិនឆ្លាត មិនអាចចូលដល់ព្រះពុទ្ធ-សាសនាបានដោយពិតប្រាកដឡើយ ព្រោះអ្នកដែលមិនឆ្លាតនោះ គឺមិនមានចិត្តរឹងប៉ឹង មិនមានសតិជាគ្រឿងរក្សាខ្លួន គោរពគុណព្រះរតនត្រ័យដោយការមិនឈ្លាសវៃ ដូច្នេះ ដើម្បីឱ្យបានចូលដល់ព្រះពុទ្ធសាសនាពិតប្រាកដ និង បានទទួលផលជាក់ស្តែងក្នុងបច្ចុប្បន្នទាន់ភ្នែកគឺត្រូវតែជាមនុស្សឆ្លាត ដើម្បីឱ្យបានជាមនុស្សឆ្លាតត្រូវឧស្សាហ៍សិក្សារៀនសូត្រថែបំប៉ននូវស្មារតី សេព-គប់ជាមួយអ្នកចេះដឹង ហើយត្រូវចងចាំជានិច្ចថា អាត្មាអញមានកិលេសព្រោះនៅល្ងង់ ។

## តួនាទីពុទ្ធបរិស័ទជាគ្រហស្ថ

**សិក្ខាបទទី៤ :** ពុទ្ធបរិស័ទជាគ្រហស្ថគប្បីសិក្សាថា អាត្មាអញត្រូវជាអ្នកមិនបិទទ្វារផ្ទះ ពោលគឺត្រូវទទួល និង ធ្វើទានចំពោះលោកអ្នកមានសីល ។

ទោះជាទ្វារផ្ទះបើកក៏ដោយ ប៉ុន្តែមិនទទួល មិនឱ្យអ្វីៗដល់អ្នកមានសីលទេ គឺឈ្មោះថាបិទទ្វារផ្ទះ ដូច្នេះពាក្យថាមិនបិទទ្វារផ្ទះ ជាឈ្មោះរបស់សទ្ធា ឯលក្ខណៈរបស់បុគ្គលអ្នកមានសទ្ធា មានបីលក្ខណៈប្រចាំខ្លួនគឺ :

១-ជ្រះថ្លាក្នុងការធ្វើទានលាងជម្រះមន្ទិលក្នុងចិត្តសន្ដាន ពេញចិត្តនឹងឱ្យសេចក្ដីសុខដល់អ្នកដទៃ



២-ជ្រះថ្លានឹងបានជួបលោកអ្នកមានសីល

៣-ជ្រះថ្លាក្នុងការស្ដាប់ធម៌របស់សប្បុរស ។

ពុទ្ធបរិស័ទជ្រះថ្លា និង តាំងចេតនាគោរពព្រះអរិយសង្ឃដែលជាសាវ័ករបស់ព្រះពុទ្ធជាម្ចាស់ ព្រោះលោកបដិបត្តិដោយល្អប្រពៃ បដិបត្តិដោយត្រង់តាមអរិយមគ្គអង្គ៨ បដិបត្តិតាមធម៌វិន័យ និង បដិបត្តិដើម្បីចេញចាកទុក្ខ កាលបើចិត្តជ្រះថ្លាយ៉ាងនេះ ពុទ្ធបរិស័ទរមែងតាមដំណើរព្រះអរិយសង្ឃ ពោលគឺធ្វើអ្វីៗតែងតែធ្វើដោយស្មោះត្រង់ត្រឹមត្រូវប្រពៃ ធ្វើតាមធម៌តាមវិន័យ ជាអ្នកដើរតាមស្នាមព្រះបាទនៃព្រះអរិយសង្ឃ មិនដើរតាមផ្លូវខ្មោចព្រាយបិសាចឡើយ ។

៙៚✧៙៚



## តួនាទីពុទ្ធបរិស័ទជាគ្រហស្ថ

**សិក្ខាបទទី៥ :** ពុទ្ធបរិស័ទជាគ្រហស្ថគប្បីសិក្សាថា អាត្មាអញត្រូវទំនុកបម្រុងនូវបច្ច័យ៤ដល់បព្វជិតក្នុងព្រះសាសនា ។

បព្វជិតក្នុងព្រះពុទ្ធសាសនា តាំងចេតនាវៀរចាកបាបទាំងពួង ជាអ្នកបួសពិតប្រាកដបដិបត្តិតាមធម៌វិន័យព្រះសាសនា ឈ្មោះថាសមណៈ ដែលហៅថាសមណៈព្រោះស្ងប់រម្ងាប់នូវបាបក្នុងចិត្ត ជាអ្នកប្រព្រឹត្តនូវការងារដ៏ប្រពៃ បានដល់ការងារសម្អាតចិត្តហ្នឹងឯង ។

សមណសក្យបុត្រមិនខ្ជិលទេ គ្រាន់តែលោកមិនបានធ្វើការងារដូចឃរាវាសប៉ុណ្ណោះ គឺលោកធ្វើតែ

ការងារណាដែលជាការងារដ៏ឧត្តមសមនឹងភេទសមណៈ ជាការងារលះបង់នូវរាគៈ ទោសៈ និង មោហៈ ជាការ-ងាររំដោះខ្លួនចេញចាកទុក្ខ មិនសន្សំទ្រព្យ មិនទុកដាក់ស្រូវអង្ករ មិនទទួលមាសប្រាក់ មិនទទួលរូបិយ មិនជាអ្នកលេងសើច មានការសង្រួមឥន្ទ្រិយដោយល្អ គ្រប់គ្រងកាយវាចាចិត្តដោយប្រពៃ ស្គាល់ប្រមាណក្នុងការស្វែងរកអាហារបិណ្ឌបាត ស្គាល់ប្រមាណក្នុងការទទួល ស្គាល់ប្រមាណក្នុងការបរិភោគ មានស្មារតីភ្ញាក់រលឹកជានិច្ច មិនជាប់ជំពាក់នឹងការដេកស្រួលឡើយ ដូច្នេះ សមណៈជាស្រែបុណ្យដ៏ប្រសើរ ។



# តួនាទីសមណព្រាហ្មណ៍
# ៦សិក្ខាបទ

## តួនាទីសមណព្រាហ្មណ៍

**សិក្ខាបទទី១** : សមណព្រាហ្មណ៍គប្បីសិក្សាថា អាត្មាអញត្រូវហាមឃាត់មនុស្សក្នុងត្រកូលទាំងឡាយកុំឱ្យធ្វើបាប ។

ញាតិញោមពុទ្ធបរិស័ទទាំងឡាយ ឱកាសដែលយើងបានជាមនុស្សក្នុងលោកនេះគ្រប់គ្នា កំពុងតែអស់ទៅហើយរាល់យប់រាល់ថ្ងៃ ។ យប់ថ្ងៃកន្លងទៅ បាននាំយកនាមរូបទៅជាមួយពុំដែលខានឡើយ ។ អាយុជីវិត ឬ ជំនាន់នៃវ័យ ចេះតែរបេះទៅវិនាសទៅគ្រប់ខណៈដែលបិទភ្នែកដេកលក់ និង បើកភ្នែកភ្ញាក់ឡើង ។ បានកើតមកជាមនុស្សម្នាក់ៗក្នុងជាតិមួយនេះ មិនជាយូរ

ប៉ុន្មានឡើយ នឹងឃ្លាតចាកទៅ បាត់បង់អស់នូវអ្វីៗដែលជាទីស្រឡាញ់ពេញចិត្ត ព្រមទាំងខន្ធ៥ ដែលបានសំគាល់ថាជាតួខ្លួនឯងនេះទៀតផង ។

សភាវៈជាអត្តភាពក្នុងជាតិនេះ នឹងត្រូវអស់ទៅ មិនអាចនៅប្រកាន់យកជាតួខ្លួនរហូតបានឡើយ កាលសាបសូន្យទៅហើយ គ្មានសល់អ្វីជាតួខ្លួនយើងទៀតទេ ដូច្នេះ កម្មត្រូវសាងអត្តភាពថ្មីយ៉ាងណា ត្រូវការពារកុំឱ្យសាងអត្តភាពថ្មីនោះជានរក ជាប្រេត ជាតិរច្ឆាន ជាអសុរកាយ ដោយការមិនធ្វើបាបហ្នឹងឯង ។



# តួនាទីសមណព្រាហ្មណ៍

**សិក្ខាបទទី២** : សមណព្រាហ្មណ៍គប្បីសិក្សាថា អាត្មាអញត្រូវណែនាំមនុស្សក្នុងត្រកូលទាំង-ឡាយឱ្យតាំងនៅតែក្នុងអំពើល្អ ។

ញាតិញោមពុទ្ធបរិស័ទទាំងឡាយ កាលណាញាតិញោមមិនធ្វើនូវបាបទាំងពួងហើយ ញាតិញោមត្រូវបំពេញនូវអំពើល្អផ្សេងៗជាបន្ថែមតទៅទៀត ប្រៀបដូចបុគ្គលកាប់ព្រៃហើយដាំដំណាំដូច្នោះឯង ឬពុំនោះសោត ប្រៀបដូចបុគ្គលងូតទឹកស្អាតហើយតាក់តែងរាងកាយដោយសម្លៀកបំពាក់ជាដើមអ៊ីចឹងដែរ ឬក៏ម្យ៉ាងទៀត ប្រៀបដូចអ្នកឈឺត្រូវតមចំណីទាស់ ហើយប្រឹង



បរិភោគនូវអាហារជាទីសប្បាយដើម្បីថែបំប៉នសុខភាពយ៉ាងដូច្នោះឯង ។

យើងមិនដឹងរឿងរ៉ាវក្នុងជាតិមុន ដែលយើងគ្រប់គ្នាបានលាចាកមកកើតជាមនុស្សក្នុងជាតិនេះឡើយ យើងមិនដឹងថាជាតិមុន អ្នកណាយំសោកស្តាយយើងខ្លះទេ ហើយយើងរឹតតែមិនដឹងថាមនុស្សសត្វដែលបានកើតជាថ្មីជុំវិញយើងសព្វថ្ងៃនេះ ធ្លាប់ជាអ្វីជាមួយនឹងយើងក្នុងជាតិមុននោះ ដូច្នេះ ទើបយើងគួរមានមេត្តាដល់គ្នា ព្រោះគេអាចជាមាតាបិតា អាចជាកូនប្រុសស្រីប្តីប្រពន្ធរបស់យើងអំពីជាតិមុនថ្មីៗនេះឯង ។

## តួនាទីសមណព្រាហ្មណ៍

**សិក្ខាបទទី៣** : សមណព្រាហ្មណ៍គប្បីសិក្សាថា អាត្មាអញត្រូវអនុគ្រោះមនុស្សក្នុងត្រកូលដោយចិត្តដ៏ល្អ ។

ការផ្សាយនូវមេត្តាចិត្តក្តី ការនាំសព្រហ្មចារីដែលមានសីលល្អចូលទៅកាន់ត្រកូលក្តី ឈ្មោះថាអនុគ្រោះត្រកូលដោយចិត្តដ៏ល្អ ។

ការធ្វើចិត្តរបស់ខ្លួនឱ្យផ្សូរផង់ អ្នកកាន់ព្រះពុទ្ធសាសនា គឺចាំបាច់ត្រូវតែដឹងរឿងនេះឱ្យបានច្បាស់លាស់ ព្រោះនេះជាចំណុចសំខាន់ក្នុងព្រះពុទ្ធសាសនា ជាធម៌បដិបត្តិដ៏ខ្ពង់ខ្ពស់ផង ជាផលដែលត្រូវបានសម្រេចផង



ដូច្នេះ ពុទ្ធបរិស័ទមិនត្រូវជាប់នៅត្រឹមតែមិនធ្វើបាប និងធ្វើតែអំពើល្អប៉ុណ្ណឹងទេ បើថាត្រឹមតែប៉ុណ្ណឹងទេនោះ ជីវិតមិនអាចរួចផុតអំពីសេចក្តីទុក្ខសោកទៅបានឡើយ ពោលគឺមិនអាចផុតរបូតអំពីកងទុក្ខទៅបាន ។

មានតែការអប់រំចិត្តឱ្យអស់កិលេសតែប៉ុណ្ណោះ ទើបអាចអស់ទុក្ខទៅបាន បុគ្គលអ្នកបង្ហាត់ចិត្តបង្វឹកចិត្តឱ្យត្រង់ ក្រៅអំពីបានចូលដល់ព្រះសាសនាយ៉ាងនៃបនិត្យហើយ នៅជាអ្នកបានឃើញព្រះសម្មាសម្ពុទ្ធយ៉ាងច្បាស់ប្រាកដដោយភ្នែកគឺបញ្ញាទៀតផង ។

៙៙✧៚៚



## តួនាទីសមណព្រាហ្មណ៍

**សិក្ខាបទទី៤** : សមណព្រាហ្មណ៍គប្បីសិក្សាថា អាត្មាអញត្រូវញ៉ាំងមនុស្សក្នុងត្រកូលឱ្យបានស្តាប់នូវធម៌ដែលមិនធ្លាប់បានស្តាប់ ។

បុគ្គលណាសម្តែងព្រះធម៌ពន្យល់អ្នកដទៃ ឱ្យឃើញច្បាស់ ឱ្យមានចិត្តអង់អាចហ៊ានសមាទានកាន់យកនូវអំពើល្អ ប្តេជ្ញាវៀរចាកបាបទាំងពួង បុគ្គលនោះឈ្មោះថាឱ្យនូវអរិយទ្រព្យដល់អ្នកដទៃ ជាអ្នកទ្រោលប្រទីបបំភ្លឺក្នុងទីងងឹត ក្នុងគំនិតគិតឱ្យមនុស្សទាំងឡាយមើលឃើញនូវផ្លូវត្រូវពិតប្រាកដ ។

ព្រះធម៌ដែលព្រះសម្មាសម្ពុទ្ធទ្រង់បានត្រាស់

សម្តែងហើយ ជារបស់សំខាន់ដ៏ក្រៃលែងក្នុងជីវិត សូមពុទ្ធបរិស័ទស្តាប់ព្រះធម៌ សិក្សាព្រះធម៌ ដើម្បីឱ្យដឹងថាខ្លួនឯងមានកិលេសច្រើនប៉ុនណា ជាមនុស្សស្អុយក្នុងព្រោះមានកិលេសក្នុងសន្តាន ហើយបានប្រព្រឹត្តទ្រុស្ត-សីលយ៉ាងណា គឺព្យាយាមស្តាប់ព្រះធម៌ដើម្បីឱ្យឃើញសេចក្តីល្ងង់ខ្លៅរបស់ខ្លួនឯងពិតៗ ។

សូមពុទ្ធបរិស័ទព្យាយាមប្តូរការគិតជាអកុសលមកជាកុសលក្នុងគំនិតវិញ សូមកុំបៀតបៀនចិត្តខ្លួនឯងត្រូវខំថ្នាក់ថ្នមថែរក្សាចិត្តឱ្យបានល្អជាទីបំផុត ។

៙៙✧៚៚



# គ្រូនាទីសមណព្រាហ្មណ៍

**សិក្ខាបទទី៥** : សមណព្រាហ្មណ៍គប្បីសិក្សាថា អាត្មាអញត្រូវបំភ្លឺសេចក្តីនៃធម៌ផ្សេងៗឱ្យមនុស្សក្នុងត្រកូលកាន់តែបានយល់ច្បាស់ចំពោះធម៌ដែលធ្លាប់ស្តាប់ហើយ ។

ចិត្តដែលបុគ្គលបានគ្រប់គ្រងថែទាំល្អហើយរមែងនាំមកនូវសេចក្តីសុខ សេចក្តីសុខបញ្ចប់បញ្ហាគ្រប់យ៉ាងក្នុងជីវិត ចិត្តដែលមានសេចក្តីសុខព្រោះបានជាសះស្បើយនូវរោគ សូមពុទ្ធបរិស័ទគ្រប់គ្នាគិតគូរសុខភាពរបស់ចិត្តផង កុំគិតតែអំពីសុខភាពរាងកាយតែម្យ៉ាងនោះ សុខភាពរបស់ចិត្តសំខាន់ណាស់ ។



ការសប្បាយរីករាយក្នុងកាមគុណ ជាចំណីទាស់របស់ចិត្តដែលមានរោគ បើមិនប្រាថ្នាឱ្យចិត្តរឹតតែដុនដាបទេនោះ ត្រូវកុំស្វែងរកសេចក្តីរីករាយភ្លើតភ្លើនក្នុងកាមគុណ ត្រូវស្វែងរកការស្តាប់ព្រះធម៌ និង បុណ្យកុសលទាំងពួង មកថែបំប៉នសុខភាពរបស់ចិត្តវិញ ដើម្បីឱ្យចិត្តមានកម្លាំងរឹងមាំឈ្នះរោគក្នុងសន្តាន ។

ការខឹងក្រោធគំនុំគុំគួន និង សេចក្តីច្រណែនឈ្នានីសជាដើម សុទ្ធតែជាគ្រឿងប្រទូសរ៉ាយនឹងចិត្តខ្លួនឯង ជាគ្រឿងបំផ្លាញសុខភាពរបស់ចិត្ត សូមពុទ្ធបរិស័ទចេះអាណិតចិត្តខ្លួនឯងផង ។

៙៙✧៚៚

## តួនាទីសមណព្រាហ្មណ៍

**សិក្ខាបទទី៦ :** សមណព្រាហ្មណ៍គប្បីសិក្សាថា អាត្មាអញត្រូវប្រាប់ផ្លូវដល់មនុស្សក្នុងត្រកូលឱ្យដើរទៅរកសុខសួគ៌និព្វាន ។

សមណព្រាហ្មណ៍គួរអនុគ្រោះអ្នកដទៃ ដោយមេត្តាករុណា និង ដោយការព្យាយាមកម្ចាត់បង់នូវកិលេសក្នុងសន្តានរបស់ខ្លួន ឱ្យបានទៅជាស្រែបុណ្យដ៏ប្រសើរ ម្យ៉ាងទៀត ដែលជាប្រយោជន៍សំខាន់បំផុតក្នុងការអនុគ្រោះ គឺអនុគ្រោះអ្នកដទៃឱ្យដឹងផ្លូវដើរទៅកាន់សេចក្ដីសុខស្ងប់យ៉ាងពិតប្រាកដ ។

មួយថ្ងៃៗ មានសុខទុក្ខរឿងរ៉ាវដែលចិត្តនឹកគិត ច្រើនជាងសុខទុក្ខតាមផ្លូវកាយ កាលណាគិតមិនល្អក្នុងរឿងអ្វីមួយ វានាំឱ្យចិត្តលំបាក ដូច្នេះ អ្នកថែរក្សាចិត្តត្រូវប្រយ័ត្នគំនិតខ្លួនឯង ជួនកាលរវល់តែគិតដល់ចិត្តមិនល្អរបស់អ្នកដទៃ ព្រោះបានដឹងថាគេធ្វើអំពើអ្វីមួយមិនគប្បី វាភ្លេចគិតដល់ចិត្តរបស់ខ្លួនឯងដែលកំពុងតែមិនល្អព្រោះកើតទោសៈ ។

នៅពេលខឹងក្រោធ យើងគិតថាមេត្តាគេមិនបានឡើយ ប៉ុន្តែក្នុងរឿងនេះត្រូវចាំថា បើមេត្តាគេមិនបាន ត្រូវតែមេត្តាខ្លួនឯងឱ្យបាន កុំដុតចិត្តរបស់ខ្លួនដោយខ្លួនឯង នេះជាផ្លូវនៃសេចក្ដីសុខស្ងប់ក្នុងជីវិត ។





## បទគួរយល់ដឹងក្នុងតួនាទី

# បទគួរយល់ដឹងក្នុងតួនាទី

យើងត្រូវមាន **សម្បជញ្ញៈ** ក្នុងតួនាទីរបស់ខ្លួន ពោលគឺសេចក្ដីដឹងខ្លួនដោយប្រពៃ ការមិនភ្លេចខ្លួន ការប្រុងប្រយ័ត្នជានិច្ច ចំពោះកិច្ចការដែលយើងត្រូវប្រតិបត្តិ ។ និយាយដល់តួនាទី មនុស្សគ្រប់គ្នាមិនមានអ្នកណាអត់ឡើយ គ្រាន់តែថាមានតិចច្រើនជាងគ្នា និងគោរពបានល្អឬមិនល្អតែប៉ុណ្ណោះ មានទាំងតួនាទីដែលត្រូវបដិបត្តិចំពោះខ្លួនឯងផ្ទាល់ មានទាំងតួនាទីដែលត្រូវធ្វើចំពោះអ្នកដទៃ មានទាំងតួនាទីដែលត្រូវធ្វើដើម្បីជាប្រយោជន៍រួមគ្នា សរុបសេចក្ដីមកគ្រប់គ្នាមានតួនាទី ។

ក្នុងឋានៈដែលយើងបានកើតមកជាមនុស្ស



យើងមានតួនាទីសំខាន់មួយជាស្រេច គឺធ្វើខ្លួនឯងឱ្យជាមនុស្ស ពោលគឺធ្វើឱ្យជាអ្នកមានចិត្តខ្ពស់ មានស្មារតីជាគ្រឿងគ្រប់គ្រង ការពារដោយប្រុងប្រយ័ត្នជាទីបំផុត មិនឱ្យខ្លួនឯងដែលមានរូបរាងជាមនុស្ស ប៉ុន្តែចិត្តគំនិតជាសត្វតិរច្ឆាន ជាខ្មោចព្រាយបិសាចនោះឡើយ ។

រូបរាងសណ្ឋានទ្រង់ទ្រាយរបស់មនុស្សមិនយកជាសំខាន់ក្នុងពាក្យថាមនុស្សនោះទេ ព្រោះពាក្យថាមនុស្សប្រែថា ជនអ្នកមានចិត្តខ្ពស់ *(មន + ឧស្ស)* គឺជនអ្នកដឹងនូវអំពើមានប្រយោជន៍ និង អំពើឥតប្រយោជន៍ ដូច្នេះ បើសិនជាបុគ្គលធ្វេសប្រហែសនៅក្នុងតួនាទីដែលខ្លួនឯងបានកើតមកក្នុងកំណើតជាមនុស្សនេះ មិនគ្រប់គ្រងរក្សាចិត្ត មិនអប់រំចិត្ត ប្រព្រឹត្តតាមតែចំណង់នៃ



កិលេសតណ្ហា សំគាល់ថាខ្លួនឯងប្រសើរជាងសត្វតិរច្ឆានត្រង់រូបរាងជាមនុស្ស វាជាការខុសធ្ងន់ណាស់ ព្រោះតាមពិត បើចិត្តមិនខ្ពស់ហើយ ដៃពីរជើងពីរនេះវាទៅជាចង្កូមដ៏មានពិស ក្រៃលែងជាងចង្កូមពស់វែកទៅទៀត ភ្នែកមុខមាត់គួរឱ្យខ្លាចជាងខ្មោចងាប់ហើមក្នុងព្រៃ រីឯពាក្យសម្ដីវិញ ថោកជាងលាមក ។

មនុស្សត្រូវតែដូចផ្កាឈូកដែលដុះក្នុងស្រះ ទឹកមិនស្អាតក្ដី ភក់ក្ដី ដែលជាទីអាស្រ័យនៃផ្កាឈូកនោះមិនប្រឡាក់ផ្កាឈូកឡើយ ផ្កាឈូកជាផ្កាដ៏ស្អាតស្រស់ដុះចេញពីទឹក តែទឹកមិនបានជោកសើមដល់ផ្កាឈូកទេ សូម្បីទីនោះជាគំនរសម្រាម ឬជាទីមិនស្អាតក៏ដោយ ផ្កាឈូកដែលដុះនៅទីនោះ គេអាចកាត់យកមកថ្វាយ

ព្រះរាជា ឬ បូជាព្រះសម្មាសម្ពុទ្ធក៏បាន ដោយចិត្តជ្រះថ្លា ព្រោះថា ជាផ្កាស្អាត មិនជិតដាមដោយរបស់មិនស្អាតឡើយ ហើយមានក្លិនក្រអូបទៀតផង ។

មនុស្សយើងគួរមានជីវិតរស់នៅដោយសេចក្តីបរិសុទ្ធ ឱ្យបានជាទីត្រេកអររីករាយនៃមហាជនក្នុងសង្គម ពិតមែនតែជាបុថុជ្ជនមានកិលេស ប៉ុន្តែអាស្រ័យសម្បជញ្ញៈធ្វើឱ្យមានចិត្តខ្ពស់ រស់នៅស្អាតស្រស់ដូចផ្កាឈូកអីចឹងឯង ដាច់ខាតកុំស្លាប់ដូចពស់ កុំរស់ដូចកង្កែប បានសេចក្តីថា ពស់មានពិសស្លាប់ទៅអ្នកភូមិត្រេកអរណាស់ ព្រោះកាលវានៅរស់ វាខាំចឹកមនុស្សព្រមទាំងគោក្របី បុរសស្ត្រីភ័យខ្លាចគ្រប់ៗគ្នា ចំណែកឯកង្កែបវិញ នៅក្នុងអណ្តូងតូចឡើងលើពុំរួច ប៉ុន្តែអួតក្អេងក្អាង



ថាកន្លែងឯងធំជាងសមុទ្រ ពុំនោះសោត បើនៅក្នុងស្រះឈូកវិញ ក៏មិនរវល់នឹងផ្កាឈូកដែលល្អមានក្លិនក្រអូបឡើយ ហើយបើនៅតាមវាលស្រែ មិនចេះកាយរន្ធអ្វីទាំងអស់ ចេះតែរំខានក្តាមតែប៉ុណ្ណោះ ធ្វើឱ្យក្តាមស្លាប់ ព្រោះខ្លួនឯងចូលក្នុងរន្ធទៅនៅពួនពីក្រោមគេទៀតផង (នៅពេលព្រានខ្វារកង្កែប ត្រូវគ្រោះថ្នាក់ក្តាមជាម្ចាស់រន្ធមុនកង្កែប) កាលភ្លៀងធ្លាក់ដក់ទឹកដើមដៃ កង្កែបគ្មានសំចៃមាត់ សប្បាយនឹងស្នេហាស្រែកឡូឡាពេញវាលស្រែ ឃើញព្រានមកដល់គ្មានខ្វល់គេច ។

មានឈ្មោះថាមនុស្សជាអ្នកមានចិត្តខ្ពស់ ថែមទាំងជាខ្មែរ ដូច្នេះ ដើម្បីឱ្យសមនឹងឈ្មោះថាជាខ្មែរ ត្រូវតែជាមនុស្សមានចិត្តក្បេម អ្នកមានចិត្តក្បេមរមែងជា



ឥស្សរៈលើប្រធាននៃសេចក្តីវិនាស មិនជាទាសៈនៃអំពើបាប មិនជាទាសៈនៃទឹកស្រវឹង មិនជាទាសៈនៃល្បែងស៊ីសង មិនជាទាសៈនៃបាបមិត្ត មិនជាទាសៈនៃសេចក្តីខ្ជិលមិនជាទាសៈនៃសេចក្តីភ្លើតភ្លើនក្នុងកាមគុណ ។

ប្រទេសខ្មែរយើងឈ្មោះថាកម្ពុជា ដូចគ្នានឹងសុវណ្ណភូមិ ប្រែថា ភូមិមាស (***កម្ពុ*** «***មាស***» + ***ជ*** ឬ ***ជា*** «***កើត កំណើត***») ភូមិប្រទេសជាទីកើតនៃមាស គឺជាដែនដីមាស ដែនដីព្រះ ព្រោះមានព្រះពុទ្ធសាសនា ដែនដីធម៌ ព្រោះមានច្បាប់សម្រាប់គ្រប់គ្រងទាំងគ្រហស្ថទាំងបព្វជិត មានវប្បធម៌សម្រាប់សាបព្រោះបណ្តុះបណ្តាលចំណេះដឹងខាងប្រាជ្ញាស្មារតី មានអរិយធម៌សម្រាប់នាំឱ្យកើតសេចក្តីសុខចម្រើន មានសណ្តាប់ធ្នាប់ល្អ មាន

ទំនៀមទម្លាប់ប្រពៃណីរបស់ជាតិខ្មែរ ។ល។ ដូច្នេះ តួនាទីជា***មនុស្ស*** + ***ខេមរៈ*** " ***ខ្មែរ*** " + ***កម្ពុជា*** ថែមទៀតនោះ គឺត្រូវតែបដិបត្តិខ្លួនឱ្យជាមនុស្សមាស ពោល គឺមានចិត្តគំនិតថ្លៃថ្នូរដូចមាស កុំថោកឱ្យសោះ ទោះជាទៅរស់នៅប្រទេសណាក៏ដោយ ឱ្យតែនៅមានឈាមខ្មែរ ឈ្មោះថាខ្មែរត្រូវតែថ្លៃថ្នូរ បើយើងថោកម្នាក់ឱ្យបរទេសដៀលត្មះ វាដោយខ្មែររាប់លាននាក់ មានឈ្មោះមិនល្អ ដោយសារយើងម្នាក់ ដូច្នេះសូមមនុស្សខ្មែរកុំធ្វើឱ្យជនបរទេសខ្ពើមប្រទេសខ្មែរ កុំបៀតបៀនជនបរទេស កុំបៀតបៀនខ្មែរគ្នាឯង និង កុំបៀតបៀនខ្លួនឯង ។

យើងជាពុទ្ធបរិស័ទ ក៏ត្រូវមានតួនាទីធ្វើខ្លួនឱ្យជាពុទ្ធបរិស័ទ គោរពព្រះធម៌ និង គោរពព្រះវិន័យ



ឱ្យបានល្អ បដិបត្តិតាមឱវាទរបស់ព្រះសម្មាសម្ពុទ្ធក្នុងភាពជាអ្នកដឹងហេតុផលច្បាស់លាស់ ជាអ្នកមានស្មារតីកែកំហុសរបស់ខ្លួន និង ជាអ្នករីករាយជ្រះថ្លាក្នុងគុណព្រះរតនត្រ័យ ។

ពុទ្ធបរិស័ទមានព្រះនិព្វានជាទិសដៅនៃដំណើរបដិបត្តិ ដូច្នេះត្រូវមានស្មារតីកំណត់ទិសដៅរបស់ខ្លួនឱ្យបានជាក់លាក់ប្រាកដ ដើម្បីកុំឱ្យរអាក់រអួលក្នុងដំណើរផ្លូវ ដែលត្រូវជួបនឹងព្រាយបិសាច ។

តាមផ្លូវទៅព្រះនិព្វាន មានភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និង ចិត្ត នៅម្ខាងផ្លូវ ហើយមានរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និង ធម្មារម្មណ៍ នៅម្ខាងទៀតនៃផ្លូវ បានសេចក្តីថា មានអាយតនៈក្នុងនិងក្រៅ



នៅអមសងខាងផ្លូវ ជាគ្រឿងទាក់អ្នកដំណើរ ដែលមានសេចក្តីប្រមាទ ដូច្នេះ សូមពុទ្ធបរិស័ទបដិបត្តិតួនាទីដោយសេចក្តីមិនប្រមាទ មិនត្រូវចាប់យកនូវអ្វីៗដែលមានតាមផ្លូវ ទោះជាមានភាពប្រណីតយ៉ាងណាក៏ដោយ ព្រោះវានៅជាសង្ខតធម៌ ត្រូវភាវនាជានិច្ចថា អ្វីៗមិនមែនជារបស់យើងគឺយើងមិនយកជាដាច់ខាត វាគ្រាន់តែជារបស់ជន្លប៉ុណ្ណោះ ជារបស់មារ ជារបស់ធ្លាក់ ។

ពុទ្ធបរិស័ទប្រយ័ត្នចិត្តប្រទូស្តផងដែរ គឺត្រូវកំណត់របស់នៅតាមផ្លូវថា ជារបស់ធម្មតាសម្រាប់ជំរុញដំណើរឱ្យបានទៅមុខ មិនត្រូវធ្វេសប្រហែសញុាំងចិត្តឱ្យប្រទូស្តជាមួយរបស់ធម្មតាដែលនៅអមសងខាងផ្លូវនោះឡើយ ព្រោះស្រឡាញ់ស្អប់គឺជាប់អន្ទាក់។

យើងជាមាតា យើងជាបិតា ក៏ត្រូវបដិបត្តិតួនាទីរបស់ខ្លួនឱ្យពេញលេញបរិបូណ៌ មានសម្បជញ្ញៈដឹងខ្លួនឯងថាជាម្ដាយគេ ឬជាឪពុកគេ មិនថាយើងនៅក្នុងតំណែងណា ឋានៈណា មានតួនាទីជាអ្វី យើងត្រូវមានស្មារតីទទួលខុសត្រូវ មានសម្បជញ្ញៈគោរពបូជា គឺបដិបត្តិដោយសេចក្ដីអត់ធន់ ត្រូវចាំជានិច្ច និង យល់ដឹងជានិច្ចថា នេះជាតួនាទីរបស់យើង ។

គេតែងពោលថា «*ខ្ញុំគ្មានការធ្វើ*»តាមពិតការងារមានច្រើនណាស់ គ្រាន់តែអ្នកខ្លះរើសអើងពេកចាត់ទុកការងារដែលមាននោះថាថោកទាបឬអន់ថយ ក៏បណ្ដោយឱ្យខ្លួនឯងទៅជាមនុស្សពិការ ទាំងដែលមានអវយវៈគ្រប់គ្រាន់អ៊ីចឹងទៅ ។

ꧏꧏ✧ꧏꧏ



# សតិសម្បជញ្ញៈក្នុងការងារ

## សតិសម្បជញ្ញៈក្នុងការងារ

ꧏ✵ꧏ

**ការងារក្នុងរង្វង់គ្រួសារ** យើងត្រូវមានសតិសម្បជញ្ញៈស្រឡាញ់រាប់អានក្រុមគ្រួសាររបស់យើង ព្រោះយើងរស់នៅក្នុងរង្វង់ក្រុមគ្រួសារ រស់នៅក្នុងវង្សត្រកូល ត្រូវថែទាំវង្សត្រកូលឱ្យបានល្អផង ។

យើងត្រូវលះបង់សេចក្ដីសុខផ្ទាល់ខ្លួន ដើម្បីប្រយោជន៍សុខដល់គ្នាច្រើននៅក្នុងក្រុមគ្រួសារ ដូចជាភរិយាស្វាមីដែលរស់នៅជាមួយគ្នាជាដើម គឺស្វាមីរស់នៅដើម្បីភរិយា ចំណែកភរិយាក៏រស់នៅដើម្បីស្វាមីរបស់ខ្លួនដែរ កាលបើមានកូនហើយ យើងជាមាតាបិតាក៏រស់នៅដើម្បីកូន ធ្វើអ្វីៗគ្រប់យ៉ាងដើម្បីកូន ។

គូភរិយាស្វាមីណា រស់នៅមិនបានបែកបាក់គ្នា ដោយការឈ្លោះទាស់ទែងលែងលះ ព្រោះភរិយាឬស្វាមីនោះ មិនបានរស់នៅដើម្បីតែខ្លួនឯងម្នាក់ប៉ុណ្ណោះឡើយ គឺជាអ្នករស់នៅដើម្បីគ្នានិងគ្នាទៅវិញទៅមក ។ ទោះជាមានការមិនត្រូវអធ្យាស្រ័យគ្នាខ្លះ ដោយរឿងខ្លះក៏ដោយ ម្នាក់ៗត្រូវតែយល់ថា វាយ៉ាងហ្នឹងឯងមនុស្សផ្សេងគ្នានោះ នឹងឱ្យត្រូវគ្នាគ្រប់រឿងទាំងអស់យ៉ាងម៉េចបានទៅ ប៉ុន្តែត្រូវចេះរៀបចំសម្រួល កុំឱ្យចេះតែគិតថាគេត្រូវតែធ្វើតាមយើងទាំងអស់នោះ សូមចាំផងចុះថា « គេមិនតាមយើងព្រោះយើងមិនតាមគេ , គេមិនដូចយើងព្រោះយើងមិនដូចគេ » ដូច្នេះ ត្រូវចេះសម្រួលអធ្យាស្រ័យគ្នាម្តងបន្តិចៗ ភរិយាទន់មក ស្វាមីទន់ទៅ



ទីបំផុតផ្លូវណាត្រូវក៏ដើរទៅទាំងពីរនាក់ ត្រូវឈរលើស្មារតីស្មោះត្រង់ស្រឡាញ់ត្រូវទាំងអស់គ្នា បើឈរលើស្មារតីយ៉ាងនេះ ប្តីប្រពន្ធរមែងដើរផ្លូវមួយជាមួយគ្នាជាផ្លូវសុភមង្គល ជាផ្លូវត្រូវ នាំគ្នាដើរទៅរកព្រះ ព្រោះបដិបត្តិតាមព្រះ ។

ម៉ែឪមិនត្រូវគ្នាធ្វើឱ្យកូនលំបាក ការចែកកូនគ្នាជារឿងកំសត់ .... ម្យ៉ាងទៀត នៅក្នុងប្រទេសមានក្មេងស្រីប្រុសឡេះឡោះប៉ៅឡែ ក៏ព្រោះបញ្ហាក្នុងក្រុមគ្រួសារជាហេតុផងដែរ ដូចជា ម៉ែឪបែកបាក់លែងលះគ្នាធ្វើឱ្យកូនរស់មិនស្រួល បរិភោគមិនរៀបរយ ទន់ខ្សោយស្មារតី កូនប្រុសស្រីអាចខូចចិត្តខ្លាំងព្រោះវិបត្តិម៉ែឪ ខ្វះការគ្រប់គ្រង ឬ គ្រប់គ្រងមិនបានល្អដោយសារម៉ែឪរវល់



ខ្វល់នឹងបញ្ហាខ្លួនឯង ជូនកាលកូនលែងស្តាប់ដំបូន្មានព្រោះចាប់កំហុសម៉ែឪហើយក៏ប្រព្រឹត្តតាមទំនើងចិត្ត ។

នៅមានទៀត គឺបញ្ហាមកអំពីម៉ែឪប្រព្រឹត្តឡេះឡោះខ្លួនឯង ឪប្រមឹកផឹកទាំងយប់ផឹកទាំងថ្ងៃវង្វេងផ្ទះសម្បែងលែងគ្រប់គ្រងប្រពន្ធកូនកើត ធ្វើឱ្យក្នុងផ្ទះរយីករយាក ...... ម៉ែខូចមារយាទនិយមអបាយមុខសំកុកវង់ល្បែង .... ទាំងនេះឯងដែលនាំឱ្យខ្ទោចព្រាយគឺអពមង្គលចូលមកដល់ក្នុងផ្ទះ ម៉ែឪឈ្លោះគ្នាជេរគ្នា ឪអាងវាយម៉ែ ចំណែកម៉ែអាងជេរឪ តើឱ្យកូនអាងអ្វីទៅ? វាជារឿងអាក្រក់អាក្រីក្រៃលែង គឺជាបាបដ៏ជ្រៅខ្មៅកខ្វក់ក្នុងគ្រួសារ ជះឥទ្ធិពលមិនល្អដល់ប្រទេសជាតិជាការទម្លាយវឌ្ឍនភាពសង្គម សរុបមកគឺជាបាបគ្រោះ

គួរជៀសវាងកុំឱ្យកើតមាននៅក្នុងគ្រួសារនីមួយៗ សូមឱ្យមាតាបិតាជាសាស្ត្រាចារ្យដ៏ល្អ និង ជាវិទ្យាល័យដ៏ល្អរបស់កូនប្រុសស្រី ។

យើងគួរអធិដ្ឋានចិត្តថា «*យើងនឹងស្រឡាញ់ ហើយនឹងថែរក្សាក្រុមគ្រួសារជានិច្ច*»យើងជាមេគ្រួសារត្រូវបំរើគ្រួសារ ស្រឡាញ់ការងារដើម្បីគ្រួសារ ធ្វើការ-ងារដោយសេចក្ដីអត់ធន់ ព្យាយាមតាំងចិត្តក្នុងការងារមិនឡេះឡោះ មិនខ្ជិលច្រអូស ដើម្បីឱ្យការងាររីកចម្រើនឈានទៅមុខ កាលបើការងាររីកចម្រើន ក្រុមគ្រួសារក៏រីកចម្រើន ខ្លួនឯងក៏បានចម្រើនតាមហ្នឹងទៅដែរ ពេលសម្រាកអំពីការងារហើយ ត្រង់មុខមកផ្ទះដោយមិនវៀចវេរ មិនទៅបំរើកាមគុណស្រីស្រា ពួក-



ម៉ាកខិលខូចឯណាឯណី ដែលជារឿងអប្រិយនាំសត្រូវចូលផ្ទះសម្លាប់ប្រពន្ធកូនឡើយ ។

យើងធ្វើការងារហើយ ត្រូវប្រញាប់រូតរះមកផ្ទះ ព្រោះយើងមានចំណងក្រុមគ្រួសារ មានអ្នករង់ចាំយើងនៅផ្ទះ យើងមករកអ្នករង់ចាំ មានពេលជួបជុំគ្នាដោយល្អជាមួយប្រពន្ធកូន អាចធ្វើការងារផ្ទះជាមួយគ្នាក៏ធ្វើដោយចិត្តភក្ដី បរិភោគបាយជាមួយគ្នាមិនមុនមិនក្រោយ ជាពិសេសភរិយានិងស្វាមី ដាច់ខាតប្រពន្ធកុំបរិភោគបាយមុនប្ដីដោយអាងថាឃ្លានណាស់ (លើកលែងតែមានករណីចាំបាច់) ហើយក៏កុំអាងថា មិនទាន់ឃ្លានចាំបរិភោគតាមក្រោយ បណ្ដោយកូន ឬ អ្នកបំរើឱ្យរៀបចំបាយទឹកជំនួសខ្លួន ដោយខ្លួនឯងមិនមានករណី



ចាំបាច់អ្វីសោះនោះ មិនប្រពៃឡើយ ។

ពេលយប់ជួបជុំកូនប្រពន្ធ ត្រូវប្រយ័ត្នរឿងទូរទស្សន៍ក្នុងផ្ទះ កុំបណ្ដោយកូនឱ្យសោះ បើមើលត្រូវមើលទាំងអស់គ្នា ហើយគប្បីអធិប្បាយឱ្យកូនស្ដាប់ថា នេះជារឿងបុណ្យ នោះជារឿងបាប ដើម្បីឱ្យកូនស្ដាប់ទៅបានយល់ដឹងកើតកើនគំនិតល្អ ពន្យល់ផ្លូវនៃជីវិតឱ្យកូនដើរទៅរកសេចក្ដីចម្រើនកើនប្រយោជន៍ ហើយត្រូវមើលឱ្យសមគួរតាមពេលវេលា មើលឱ្យមានប្រយោជន៍ រួចហើយឱ្យកូនអានសៀវភៅ និង ធ្វើកិច្ចការរៀនសូត្រ ... ជាម៉ែជាឪត្រូវរួមគ្នាជួយអប់រំកូន ដើម្បីគ្រួសារមួយដ៏ភ្លឺស្វាង ដើម្បីប្រទេសជាតិយើងបានរុងរឿងតទៅ ។

៙៙✧៚៚

## សតិសម្បជញ្ញៈក្នុងការងារ

**ការងារដើម្បីប្រទេសជាតិ** យើងត្រូវមានសតិសម្បជញ្ញៈស្រឡាញ់ជាតិគឺមនុស្សទាំងអស់ក្នុងប្រទេសរបស់ខ្លួន យើងត្រូវតាំងចិត្តធ្វើបុណ្យជាមួយមនុស្សរាប់លាននាក់ ដោយស្មារតីស្រឡាញ់ និង គោរពប្រទេសជាតិ យើងប្រាថ្នាឱ្យមនុស្សគ្រប់គ្នាបានរស់នៅជាសុខក្សេមក្សាន្ត ។

ធ្វើការងារដើម្បីប្រទេសជាតិ ព្រោះស្រឡាញ់ជាតិ ពោលគឺការឃើញដល់ប្រយោជន៍រួមរបស់ជនរួមជាតិ មិនឃើញតែប្រយោជន៍ផ្ទាល់ខ្លួន ម្ល៉ោះហើយធ្វើការងារអ្វីៗក៏ធ្វើដើម្បីប្រយោជន៍រួម មិនធ្វើដើម្បីតែ



ប្រយោជន៍ផ្ទាល់ខ្លួនឯងឡើយ ។

ស្រឡាញ់ជាតិ គឺស្រឡាញ់មនុស្សច្រើននាក់មានបំណងធ្វើបុណ្យជាមួយមនុស្សទាំងអស់គ្នា យើងត្រូវគិតថា ខ្លួនយើងម្នាក់ៗ ឬមនុស្សក្នុងរង្វង់គ្រួសារប៉ុន្មាននាក់នោះ វាតិចតួចតួចតាចទេ ជាតិធំជាងព្រោះមានមនុស្សច្រើននាក់ ទាំងគ្រហស្ថ ទាំងបព្វជិត ដូច្នេះស្មារតីស្រឡាញ់ប្រទេសជាតិ គឺធ្វើអ្វីៗរមែងនឹកដល់មនុស្សដ៏ច្រើនក្នុងប្រទេសរបស់ខ្លួន ហើយអ្នកដែលអាចស្រឡាញ់ប្រទេសជាតិបាន គឺមនុស្សគ្រប់គ្នាទាំងអស់ ។

គ្រប់ពេលទាំងអស់ ជាពិសេសគឺបច្ចុប្បន្ននេះឯងដែលប្រទេសជាតិត្រូវការមនុស្សស្រឡាញ់ ជាការស្រឡាញ់យ៉ាងពិតប្រាកដ ជាអ្នកហ៊ានលះបង់អ្វីៗដើម្បី



ប្រយោជន៍រួម ជាអ្នកធ្វើការដោយចិត្តបរិសុទ្ធយុត្តិធម៌ស្មោះស្មើ មិនធ្វើដោយសេចក្ដីលំអៀងព្រោះស្រឡាញ់ ព្រោះស្អប់ ព្រោះវង្វេង និង ព្រោះខ្លាចឡើយ ។

សតិសម្បជញ្ញៈស្រឡាញ់ប្រទេសជាតិ គឺមិនយកនូវតំណែងមុខនាទីមកដើម្បីស្វែងរកផលប្រយោជន៍សម្រាប់តែខ្លួនឯង និង ក្រុមគ្រួសារតូចមួយរបស់ខ្លួនប៉ុណ្ណោះទេ មិនយកការចេះដឹង និង សមត្ថភាពគ្រប់គ្រាន់របស់ខ្លួនមកបំរើកិលេសតណ្ហារបស់ខ្លួននោះឡើយ ការចេះដឹងនៃមនុស្សម្នាក់ៗ អាស្រ័យសាលារៀន លោកគ្រូអាចារ្យ មាតាបិតា ។ល។ សរុបមកគឺប្រទេសជាតិមានគុណលើយើង ដូច្នេះ យើងគប្បីដឹងគុណដល់ប្រទេសជាតិដែលបានផ្ដល់នូវចំណេះដឹងដល់យើង ហើយយើង

អាស្រ័យចំណេះដឹងនោះសងគុណចំពោះប្រទេសជាតិវិញ ដូចបានបញ្ជាក់រួចហើយថា ស្រឡាញ់ជាតិគឺស្រឡាញ់មនុស្សច្រើនលាននាក់ ដូច្នេះ ការដឹងគុណ និង ការសងគុណដល់ប្រទេសជាតិ គឺជាការធ្វើបុណ្យប្រារព្ធដល់អ្នកមានគុណច្រើននាក់ ដែលជាបុព្វការីរបស់យើងនៅក្នុងប្រទេសហ្នឹងផង ជួយមនុស្សដ៏ច្រើនទៀតផង ។

សូមឱ្យមនុស្សទាំងឡាយ មានសតិសម្បជញ្ញៈរឿយៗប្រចាំជីវិតដូច្នេះថា មនុស្សយើងកើតមកខ្លួនទទេដៃទទេ បន្តិចទៀតស្លាប់ទៅវិញក៏ដៃទទេដែរ មិនបានយកអ្វីពីលោកនេះទៅឡើយ បដិសន្ធិក្នុងភពថ្មីយកទៅបានតែបុណ្យ និងបាប ព្រមដោយឧបនិស្ស័យតែប៉ុណ្ណោះ ដូច្នេះ ទើបយើងមិនត្រូវលោភលន់ហួសប្រមាណនោះ



ឡើយ យើងគួរកើតមកដើម្បីសេចក្ដីចម្រើនដល់មនុស្សច្រើននាក់ យើងត្រូវតែជាមនុស្សព្រហ្មម្នាក់សម្រាប់សាងលោក ញុំាងលោកឱ្យចម្រើន មិនមែនកើតមកដើម្បីដុតបំផ្លាញនូវលោកដូចភ្លើងឆេះកល្បនោះឡើយ ។

ក្រោកព្រឹកឡើងគួរអធិដ្ឋានចិត្តថា « *ថ្ងៃនេះអាត្មាអញត្រូវមានជីវិតដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខដល់មនុស្សទាំងឡាយ* » សប្បាយចិត្តត្រង់ដែលខ្លួនឯងម្នាក់ អាចមានសមត្ថភាពញុំាងប្រយោជន៍ឱ្យដល់មនុស្សរាប់លាននាក់ដោយធ្វើការងារប្រចាំថ្ងៃ ទោះបីយើងយកប្រាក់ខែប្រាក់ថ្ងៃពិតមែន ប៉ុន្តែយើងរស់ដើម្បីប្រទេសជាតិ ដើម្បីប្រជាជន ដូចជា លោកគ្រូ អ្នកគ្រូបានប្រាក់ខែគ្រាន់តែសម្រាប់រស់ ឯចំណែកចិត្តបុណ្យគឺ



អនុគ្រោះដល់សិស្ស ប្រាថ្នាការចេះដឹងឱ្យដល់មនុស្សច្រើននាក់ ធ្វើជាពេទ្យព្យាបាលរោគតាំងចិត្តជាបុណ្យរមែងបានបុណ្យដោយពិត ព្រោះបុណ្យសម្រេចនៅត្រង់ចិត្តល្អ ឯចំណែករឿងយកប្រាក់ខែគឺសម្រាប់រស់ ព្រោះបើមិនរស់ ធ្វើការអ្វីក៏មិនកើតដែរ ទោះជាធ្វើការងារអ្វីក៏ដោយ ឱ្យតែដើម្បីជួយអ្នកដទៃ ដើម្បីសេចក្ដីចម្រើនក្នុងសង្គម ឈ្មោះថាមនុស្សចិត្តបុណ្យ គឺជាមនុស្សដែលមានទេវតាស្ថិតក្នុងចិត្ត សូមមនុស្សលោកគ្រប់គ្នាអធិដ្ឋានកុំឱ្យនរកប្រេតមកស្ថិតនៅក្នុងចិត្តរបស់ខ្លួន សូមឱ្យព្រះគឺសេចក្ដីស្មោះត្រង់ សេចក្ដីអត់ធន់ ស្មារតីរឹងប៉ឹង និងសម្បជញ្ញៈមកស្ថិតជំនួសវិញអស់កាលជានិច្ចចុះ សូមវេរប្រគល់ចិត្តរបស់យើងថ្វាយព្រះ ទុកជាព្រះធម្មចេតិយគឺចេតិយធម៌ ។

មនុស្សមានសេចក្តីស្រឡាញ់ប្រទេសជាតិត្រឹមត្រូវ ហៅថាជាមនុស្សចម្រើន ជាមនុស្សមានគុណធមិ មានវឌ្ឍនធមិ មានអ្វី១សុទ្ធតែល្អ១ទាំងអស់ ហើយភូមិស្រុកប្រទេសជាតិរបស់យើង ត្រូវការមនុស្សល្អបែបនេះ ជាមនុស្សមានគុណធមិប្រចាំចិត្ត ។ សូមឱ្យមនុស្សលោកចេះខ្ពើមគ្រឿងសៅហ្មងស្មោកគ្រោករបស់ខ្លួនឯង កុំទុកឱ្យតែអ្នកដទៃគេខ្ពើមឆ្អើមនោះ សូមឱ្យមនុស្សលោកបាននូវការចេះដឹងដ៏សំខាន់មួយ គឺដឹងថាខ្លួនឯងមាននូវកំហុសដែលត្រូវកែប្រែ ។

យើងជាមនុស្សម្នាក់ ដែលហៅខ្លួនឯងថាជាមនុស្ស ហៅថាជាខ្មែរ ហៅថាជាពុទ្ធបរិស័ទ កាលបើយ៉ាងដូច្នេះ យើងមិនអាចមានត្រឹមតែឈ្មោះនោះទេ គឺត្រូវមានទឹកចិត្តភ្ញាក់កំណើតកើតគំនិតប្រព្រឹត្តល្អ ឱ្យ



សមនឹងឈ្មោះ សូមឱ្យយើងតាំងចិត្តសន្សំបុណ្យ សន្សំគុណធមិ មានមេត្រីភាពស្រឡាញ់មនុស្សជាតិដូចគ្នា មិនបៀតបៀនដល់សត្វទាំងឡាយ រាប់អានព្រះពុទ្ធសាសនាដោយស្មោះត្រង់ប្រកបដោយសទ្ធា និង បញ្ញា ស្រឡាញ់ជាតិមាតុភូមិ ស្រឡាញ់ការងារតាមតួនាទី ស្រឡាញ់វង្សត្រកូលក្រុមគ្រួសារ មានចិត្តមេត្តាប្រាថ្នាឱ្យមនុស្សសត្វទាំងឡាយ រស់នៅដោយមិនមានពៀរវេរា មានបំណងល្អដល់គ្នានិងគ្នារាល់ថ្ងៃ មិនគប្បីស្អប់គ្នាឡើយ ។



## ហេតុផលក្នុងធម្មជាតិ

αក្នុងធម្មជាតិទាំងពួងសុទ្ធតែមានហេតុ មានផល អ្វី១ដែលមិនកើតឡើងព្រោះអត់មានហេតុ កាលណាបើមានហេតុដល់ព្រម ផលទើបកើតឡើងបាន ។ មនុស្សម្នាក់ធ្វើល្អមិនបាន ព្រោះហេតុនៃអំពើល្អនោះមិនមាន វាមានតែហេតុនៃអំពើអាក្រក់ ទើបអំពើអាក្រក់ប្រព្រឹត្តទៅបាន នេះជាច្បាប់ហេតុផលក្នុងធម្មជាតិ ។ សង្ខារធម៌ទាំងអស់បង្គាប់បញ្ជាមិនបានឡើយ ព្រោះហេតុដូច្នេះហើយ យើងអាចពិចារណាកាត់បន្ថយនូវការប្រកាន់ថា បុគ្គលនោះជាអ្នកមិនធ្វើអំពើល្អ ។

# មនុស្សចេះគិត

# មនុស្សចេះគិត

**គំនិតកូនល្អ** គុណរបស់មាតាបិតាប្រៀបជាមួយរបស់សុទ្ធតែធំៗឬធ្ងន់ៗដូចជាផែនដី ភ្នំព្រះសុមេរុ ឬ លំហអាកាសមហាសមុទ្រជាដើម ជីវិតយើងជាកូនត្រូវបានសម្ព័ន្ធគ្នាជាមួយមាតាបិតា ដែលជាបុគ្គលមុនដំបូងបង្អស់ និង ជាបុព្វការីរបស់កូនប្រុសស្រី ដូច្នេះទើបយើងត្រូវនឹករលឹកដោយគំនិតល្អថា តើយើងជាកូនត្រូវតបស្នងសងគុណលោកវិញយ៉ាងណា?

តាមការត្រាស់សម្តែងរបស់ព្រះសម្មាសម្ពុទ្ធ គឺត្រូវឱ្យកូនមានគំនិតល្អថា មាតាបិតាលោកបានចិញ្ចឹមបីបាច់ថែរក្សាអាត្មាអញមកយ៉ាងណា អាត្មាអញត្រូវ



ចិញ្ចឹមបីបាច់ថែរក្សាលោកវិញដោយការដឹងគុណ និងដោយការពេញចិត្តចំពោះសេចក្តីល្អ ដែលខ្លួនឯងជាកូនត្រូវសន្សំទុកក្នុងសន្តាន ជួយធ្វើកិច្ចការងារជំនួសលោកដោយទឹកមុខស្រស់បស់ ប្រព្រឹត្តនូវអំពើត្រឹមត្រូវសមភ្នែកអ្នកផងទាំងពួង ចូលក្នុងគន្លងមនុស្សល្អ បដិបត្តិនូវសុជីវធម៌ធ្វើឱ្យមាតាបិតាសប្បាយចិត្ត គឺជាកូនរក្សាវង្សត្រកូល សមគួរនឹងទទួលនូវទ្រព្យមរតក និងម្យ៉ាងទៀត កាលមាតាបិតាគាត់មាននូវជម្ងឺរោគា គប្បីកូនប្រុសស្រីបីបាច់ថែរក្សា ទោះបីដឹងថាមើលមិនជាយ៉ាងណាក៏ដោយ ត្រូវជួយឱ្យគាត់សប្បាយចិត្តមុនពេលគាត់លាចាកលោកទៅ កុំឱ្យមានចិត្តសៅហ្មងមុនពេលស្លាប់ កាលបើមាតាបិតាធ្វើកាលកិរិយាទៅហើយ កូនប្រុសស្រី

ត្រូវធ្វើបុណ្យទក្ខិណានុប្បទាន ដើម្បីឧទ្ទិសទូវទក្ខិណា-ទានជូនដល់លោកដែលបានចែកឋានទៅនោះ ។

ការចិញ្ចឹមលោកអ្នកមានគុណ ជាពិសេសនៅពេលគាត់ចូលដល់វ័យចាស់ជរា គឺមានការចិញ្ចឹម ២យ៉ាងបានដល់ ការចិញ្ចឹមកាយ ១ ចិញ្ចឹមទឹកចិត្ត ១ ។ ចិញ្ចឹមកាយ គឺចាត់ទីកន្លែងលំនៅស្ថានឱ្យបានសប្បាយជូនគាត់ទាំងពីរនាក់ កុំទាល់តែគាត់ធ្វើមរណកាលទៅទើបបានគិតគូររកលំនៅស្ថានជូនគាត់នោះ ជួនកាលធ្វើម៉ុង ឬចេតិយដើម្បីបញ្ចុះសពបញ្ចុះធាតុ ភ្លេចគិតដល់ជីសង្ឃទៀតផង ដូច្នេះ កូនត្រូវចេះគិតឱ្យបានសព្វគ្រប់កុំឱ្យថ្លោះធ្លោយ គឺពេលដែលគាត់នៅរស់ហ្នឹងហើយ កូនត្រូវចេះសន្សំបុណ្យ មើលអាហារបាយទឹករៀបជូនគាត់ពិសា



ចំណីណាល្អឆ្ងាញ់ទិញជូនគាត់ ទិញមកថ្លៃកុំកុហកគាត់ថាថោក ត្រូវលួងលោមសន្តានចិត្តគាត់ថាកូនចង់បានបុណ្យច្រើន កូនចង់ធ្វើបុណ្យជាមួយមាតាបិតាដែលជាព្រះអរហន្តរបស់កូន សូមលោកឪពុកអ្នកម្តាយអនុគ្រោះទទួលទានរបស់កូនផងចុះ មើលសំលៀកបំពាក់របស់គាត់ បើប្រឡាក់ត្រូវយកទៅបោកគក់ ស្ងួតហើយរៀបចំបត់ទុកដាក់ក្នុងទូ ឬហិបអប់គ្រឿងក្រអូប បន្ទប់ដំណេកគ្រែពូកកន្ទេលខ្នើយមុងភួយកុំឱ្យទុកទាល់តែស្អុយរលួយត្រូវសម្អាតជារឿយៗ រៀបចំឱ្យល្អដូចបន្ទប់របស់ទេវតាក្នុងស្ថានសួគ៌ា បើគាត់មានជម្ងឺឈឺថ្កាត់នានា កូនគួរគប្បីថែរក្សាយ៉ាងណានឹងអធិប្បាយតាមក្រោយ នេះជាកិច្ចការទំនុកបម្រុងផ្នែករាងកាយអធិប្បាយដោយសង្ខេប ។



ចំណែកការចិញ្ចឹមទឹកចិត្តនោះ គឺថាយើងជាកូនកុំចេះតែធ្វើអ្វីៗ ដែលមិនគួរគប្បីដល់អធ្យាស្រ័យរបស់គាត់ ព្រោះវាជាហេតុបណ្តាលឱ្យគាត់មានចិត្តក្តៅក្រហាយ ត្រូវចេះរៀបចំសម្រួលកិច្ចការគ្រប់យ៉ាងដើម្បីឱ្យអ្នកមានគុណរបស់យើងគាត់បានធូរចិត្ត គាត់រីករាយសប្បាយ ទៅណាមកណាឬធ្វើកិច្ចការអ្វីៗត្រូវនឹកដល់ឪពុកម្តាយជានិច្ចថា គាត់ត្រូវការអ្វី ហើយគាត់មិនចង់បានទូវអ្វី មិនចង់ឃើញនូវអ្វី មិនចង់ជួបប្រទះនូវអ្វីយើងត្រូវចេះគិតដោយគំនិតល្អ ក្នុងបំណងប្រាថ្នាថែរក្សាទឹកចិត្តឪពុកម្តាយយើង កុំចេះតែធ្វើអ្វីៗតាមទំនើងចិត្តព្រោះយើងមានមនុស្សដ៏សំខាន់នៅរួមសុខទុក្ខជាមួយ ។ យើងមិនត្រូវធ្វើនូវអ្វីៗដែលទំនាស់នឹងបំណងរបស់គាត់

ឡើយ ហើយក៏មិនត្រូវធ្វើនូវការងារអ្វីៗដែលជាទោស ផងដែរ ត្រូវធ្វើឱ្យសមស្របតាមបំណងប៉ងប្រាថ្នារបស់មាតាបិតាទាំងដែលជាការងារប្រាសចាកទោស គឺជាការចិញ្ចឹមទឹកចិត្ត ជាការចិញ្ចឹមដ៏សំខាន់ជាងការចិញ្ចឹមរូបកាយទៅទៀត ព្រោះថាបើចិត្តសប្បាយហើយ រូបកាយក៏សប្បាយទៅផងដែរ ពិសាបានសម្រាន្តលក់ បើចិត្តមិនសប្បាយទៅវិញ កាយក៏មិនសប្បាយដែរ មិនជាសុខសម្រាន្តឡើយ ព្រោះហេតុនេះ កូនប្រុសស្រីត្រូវចិញ្ចឹមទឹកចិត្តមាតាបិតាដោយការយកចិត្តទុកដាក់ ត្រូវថែរក្សាទឹកចិត្តរបស់គាត់ ដោយការប្រព្រឹត្តល្អរបស់យើងជាកូនដែលចេះគិតហ្នឹងឯង ។

ដោយចំពោះមែនទែន គឺនៅពេលដែលមាតា



បិតាចាស់ជរា ត្រូវយកចិត្តទុកដាក់ឱ្យជាពិសេសបំផុត អាហារណាគាត់ចូលចិត្តពិសា ត្រូវសិក្សាឱ្យច្បាស់លាស់ ត្រូវព្យាយាមរកមកជូនគាត់ពិសា ថែបំប៉នព្រឹកល្ងាច ពេលគាត់ឈឺថ្កាត់គ្រុនរងា គឺត្រូវយកចិត្តទុកដាក់ថែរក្សាដោយខ្លួនឯងផ្ទាល់ កុំអាងមានប្រាក់ដុល្លារជួលអ្នកបំរើ ហើយខ្លួនឯងមិនរវល់នឹងគាត់នោះ ព្រោះអ្នកបំរើ ឬអ្នកដទៃ មិនមែនជាកូនរបស់គាត់ មិនបានឱ្យការសប្បាយចិត្តដល់គាត់ដូចយើងជាកូនបង្កើតនោះទេ គាត់ចង់ឃើញមុខកូនគាត់ គឺមុខមនុស្សដែលគាត់បានបង្កើត បានស្រឡាញ់ បានថ្នាក់ថ្នមបីបមថែរក្សាតាំងពីកើតចេញអំពីផ្ទៃរបស់គាត់មកម្ល៉េះ ទោះបីសព្វថ្ងៃកូនគាត់ចាស់អាយុ ៥០ឆ្នាំហើយក៏ដោយ ក៏គាត់នឹកចង់ឃើញមុខដែរ ឃើញ



ហើយសប្បាយចិត្តថាពិតជាកូនគាត់មែន បើកូនគាត់ច្របាច់ដៃច្របាច់ជើងជូនគាត់នោះ គាត់កក់ក្ដៅក្នុងចិត្ត ដោយមិនក្រែងរអែងអ្វីឡើយ គាត់ចង់ឱ្យកូនអង្គុយជិតៗ បើកូនមកអង្គុយជិតៗគាត់ហើយ គាត់សប្បាយចិត្ត មិនសប្បាយរឿងអ្វីដែលចម្លែកនោះទេ គឺសប្បាយត្រង់ដែលថាកូននៅស្រឡាញ់គាត់ យកចិត្តទុកដាក់ជាមួយគាត់ ដូច្នេះត្រូវប្រយ័ត្នកុំឱ្យមាតាបិតានឹកអន់ចិត្តជាមួយយើងឱ្យសោះ ។

ធ្លាប់មានតួយ៉ាងចំពោះកូនខ្លះ ប្រព្រឹត្តទាស់អធ្យាស្រ័យរបស់ម៉ែពេលគាត់ឈឺ មិនឧស្សាហ៍មកសួរសុខទុកគាត់ឡើយ ពេលសរសេរសំបុត្រមកម៉ែ ខ្លួនឯងមិនសរសេរទេ បង្គាប់ប្រពន្ធឱ្យសរសេរ ម៉ែអានហើយ

មុខមិនស្រស់ ព្រោះមិនមែនអក្សរកូនប្រុស មិនបានឃើញមុខកូនប៉ុន្តែឱ្យបានឃើញអក្សរកូនទៅចុះ នេះមិនបានទៀត ខ្លួនឯងពេទ្យដែរតែមិនមកមើលម៉ែ ពឹងពាក់មិត្រភ័ក្តិឱ្យមកជំនួសទៅវិញ ខ្លួនឯងធ្វើព្រងើយកន្តើយមិនរវល់យកចិត្តទុកដាក់ ម៉ែមិនសប្បាយចិត្ត ... សរុបមក ព្រោះស្រឡាញ់កូន ចង់ឱ្យកូនយកចិត្តទុកដាក់ជាមួយ ប៉ុន្តែបែរជាកូនមិនចេះគិត ជាមនុស្សអត់គំនិតដោយមិនចេះគិតថា ទឹកចិត្តរបស់មនុស្សចាស់ជាម៉ែជាឪគិតកូនយ៉ាងណា បំណងប្រាថ្នារបស់មនុស្សចាស់យ៉ាងម៉េចខ្លះ មិនបានសិក្សាឱ្យយល់ដឹង តាមពិត មនុស្សអាយុច្រើនចូលដល់ចាស់ជរា ច្រើនតែប្រែត្រឡប់មកស្រដៀងនឹងកូនតូច ពោលគឺចូលចិត្តអ្នកនៅជិត ត្រូវការអ្នកយក



ចិត្តទុកដាក់ថែទាំចិញ្ចឹមរក្សា តើអ្នកណាដែលត្រូវនៅជិតយកចិត្តទុកដាក់នឹងគាត់ ? គឺកូនគាត់ហ្នឹងឯង ដូច្នេះ កូនម៉ែ កូនឪ ត្រូវតែជាកូនឱ្យពិតប្រាកដ ឧស្សាហ៍ចូលជិតសាកសួរសុខភាព ឪម៉ែមានជម្ងឺត្រូវប្រញាប់រូតរះមកថែរក្សា មកត្រួតពិនិត្យចាត់ចែងថ្នាំយ៉ាងណា សរុបមក គឺការយកចិត្តទុកដាក់ធ្វើឱ្យគាត់សប្បាយចិត្ត ។

សូមឱ្យនឹកដល់កាលយើងនៅតូច ពេលយើងឈឺម៉ែឪយ៉ាងម៉េចខ្លះចំពោះយើង គឺគាត់ភ័យណាស់ មុខគាត់ស្លេកស្លាំងស៊ីងរកឈាមគ្មាន ប្រញាប់ប្រញាល់មិនថាយប់អធ្រាត្ររកថ្នាំរកពេទ្យជួយកូនឱ្យជា កូននៅមិនសុខម៉ែឪសំកុកមិនព្រមសម្រាន្ត នៅព្រួយនៅគិតចិត្តមិនក្សេមក្សាន្ត លុះត្រាកូនបានស្បើយទើបផុតភ័យ ។



គុណមាតាបិតាសរសេរមួយសៀវភៅមិនចប់ឡើយ ណើ្ហយ សង្ខេបប៉ុណ្ណឹងចុះ ! ទុកឱ្យកូនប្រុសស្រីជាមនុស្សចេះដឹងគិតតទៅទៀត ព្រោះកិច្ចការបំរើមាតាបិតាជាមង្គលដ៏ឧត្តម ត្រូវកូនខំគិតឱ្យយល់ក្នុងសេចក្តីទាំងអស់នេះ ហើយបដិបត្តិដើម្បីឈានទៅរកភាពភ្លឺស្វាងរុងរឿងនៃជីវិតកុំបីអាក់ខានឡើយ ។

៚✧៙

# មនុស្សចេះគិត

**គំនិតអ្នករៀនសូត្រ** ការសិក្សារៀនសូត្រ មិនមានថ្នាក់បញ្ចប់ ទោះបីយើងមានឋានៈជាគ្រូបង្រៀននូវវិជ្ជាផ្សេងៗក៏ដោយ ប៉ុន្តែពេលខ្លះយើងក៏ជាសិស្សដែរ កាលបើយើងជាសិស្ស តើយើងត្រូវធ្វើយ៉ាងណា ? គឺយើងត្រូវបន្ទាបខ្លួនបង្អោនចិត្ត ព្រមទទួលស្តាប់នូវពាក្យណែនាំ និង ពាក្យដាស់តឿនរបស់មនុស្សផ្សេងៗ ដែលគេនិយាយឱ្យយើងស្តាប់ មានមនុស្សខ្លះចរិតរឹងរូស មិនបង្អោនចិត្តដើម្បីស្តាប់ពាក្យអ្នកដទៃ គឺចូលចិត្តតែខាងនិយាយឱ្យគេស្តាប់ប៉ុណ្ណោះ ។

មនុស្សដែលជាអ្នកនិយាយល្អនោះ ត្រូវតែជា



អ្នកស្តាប់ដោយល្អផង ចំណុចនេះសំខាន់ណាស់ សូម្បីព្រះសម្មាសម្ពុទ្ធជាអង្គម្ចាស់ក៏ព្រះអង្គស្តាប់សាវ័កសម្តែងធម៌ដែរ គឺព្រះអង្គស្តាប់ដោយការគោរពព្រះធម៌ ដូច្នេះក្នុងសេចក្តីនេះ កាលណាគេឱ្យយើងនិយាយ យើងក៏និយាយ ប៉ុន្តែកាលណាដល់ពេលយើងស្តាប់ យើងត្រូវស្តាប់ដោយសេចក្តីគោរព នេះគេហៅថាគំនិតអ្នកសិក្សារៀនសូត្រ ស្តាប់ហើយមានការយល់ខុស ឬ យល់ត្រូវយ៉ាងណា នៅលើមនសិការរបស់យើងទេ មនុស្សយើងបើមិនព្រមស្តាប់ពាក្យអ្នកដទៃនិយាយផងទេនោះ គឺដូចជាបិទទ្វារបិទបង្អួចផ្ទះអ៊ីចឹងឯង វារមែងងងឹតជាធម្មតា បើយើងបើកទ្វារបើកបង្អួច ពន្លឺរមែងចូលមកក្នុងផ្ទះយ៉ាងណា ជីវិតយើងក៏ដូចគ្នា បើយើងមិនទទួលការចេះ



ដឹងអំពីអ្នកដទៃហើយ វាមិនមានអ្វីបន្ថែមលើការចេះដឹងរបស់យើងឱ្យរឹតតែភ្លឺស្វាងឡើងឡើយ ហើយយើងក៏មិនរឹងរឹតតែឆ្លាតទៀតបានដែរ ដូច្នេះ យើងត្រូវតែទទួលស្តាប់ពាក្យអ្នកដទៃនិយាយផង ដោយស្មារតីប្រុងប្រយ័ត្ន និង យកចិត្តទុកដាក់បំផុត ទោះបីអ្នកនិយាយនោះយើងគិតថា គេមិនមានការសិក្សាយ៉ាងណាក៏ដោយ តែពេលខ្លះគេក៏និយាយគួរស្តាប់ដូចគ្នា គេនិយាយតាមការយល់របស់គេ តាមការចូលចិត្តរបស់គេ សូម្បីក្មេងតូចៗ ពេលខ្លះក៏និយាយគួរឱ្យយកចិត្តទុកដាក់ពិចារណាផងដែរ ។

មិនចាំបាច់តែសំដីមនុស្សទេ អ្វីៗទាំងអស់ដែលមានក្នុងពិភពលោកនេះ ជាពិសេសនៅជុំវិញខ្លួនយើង

សព្វថ្ងៃ គឺសុទ្ធតែគួរដល់ការសិក្សារៀនសូត្រទាំងអស់ ព្រោះជាធម្មជាតិ អាចឱ្យយើងយល់ដឹងក្នុងរឿងជីវិតបាន បើយើងយកចិត្តទុកដាក់សិក្សាពិចារណារឿយៗ ។

យើងសិក្សាអំពីធម្មជាតិ ក្នុងធម្មជាតិមានខន្ធ ៥ មានអាយតនៈ ១២ ធាតុ ១៨ ទាំងអស់នេះសុទ្ធតែជាមេរៀនសំខាន់ៗដែលគួរដល់ការសិក្សា ហើយក្នុងធម្មជាតិ មានហេតុផលបញ្ជាក់ប្រាប់ការពិត ដើម្បីជាគ្រឿងចម្រើនបញ្ញា ប៉ុន្តែបើសិក្សាយល់ខុសអំពីហេតុផល នាំឱ្យមានមិច្ឆាទិដ្ឋិផ្សេងៗ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងអំពីមិច្ឆាទិដ្ឋិរបស់មនុស្សទាំងឡាយ ព្រមទាំងមិច្ឆាទិដ្ឋិរបស់ទេវតា និង មិច្ឆាទិដ្ឋិរបស់ព្រហ្មទៀតផង ព្រះអង្គទេសនាពន្យល់



សត្វលោកសព្វគ្រប់ ព្រះអង្គត្រាស់សម្ដែងអំពីសង្ខារធម៌គ្រប់យ៉ាងដែលមានក្នុងលោក អ្វីជាគុណ អ្វីជាទោស អ្វីដែលមានប្រយោជន៍ និង អ្វីដែលមិនមានប្រយោជន៍ ហើយសម្មាទិដ្ឋិនោះយ៉ាងណា ព្រះអង្គទ្រង់ត្រាស់សម្ដែងទាំងអស់ ដូច្នេះ យើងត្រូវយកចិត្តទុកដាក់សិក្សារៀនសូត្ររាល់ថ្ងៃ ដើម្បីកសាងខ្លួន ឱ្យបានប្រសើរឡើង ។

មនុស្សយើងភាគច្រើនណាស់ ដែលយល់ខុសក្នុងមង្គលនៃជីវិត តែងប្រកាន់មង្គលនៅលើថ្ងៃខែឆ្នាំ ឬពេលវេលា ប្រកាន់ចំពោះទៅលើវត្ថុផ្សេងៗ ទីកន្លែង ។ល។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងមង្គលជីវិតមាន ៣៨ប្រការ គួរមនុស្សយើងគ្រប់គ្នាសិក្សាឱ្យបានយល់ដឹង ដើម្បីសុភមង្គលនៃជីវិតខ្លួនឯងផ្ទាល់ផង សុភ-



មង្គលនៅក្នុងគ្រួសារផង ប្រទេសជាតិបានចម្រើនរុងរឿងផង ។

*✍ ឱកាសដែលបានមកជាមនុស្ស កំពុងតែអស់ទៅរៀងរាល់យប់ថ្ងៃ ពេលវេលាដែលបាននៅជាមនុស្សក្នុងជាតិនេះ សល់មិនច្រើនទេ ទាំងដែលមិនបានដឹងប្រាកដថា ត្រូវអស់ទៅនៅពេលណាទៀតផង ដូច្នេះទើបមិនត្រូវឱ្យហួងហែងអ្វីៗពេកនោះឡើយ ត្រូវខំអប់រំចិត្តដោយការចម្រើនបញ្ញា ។*

## មង្គល ៣៨ប្រការ

១- កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ ។

២- កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ ។

៣- កិរិយាបូជាដល់បុគ្គលដែលគួរបូជាទាំងឡាយ ។

៤- កិរិយានៅក្នុងប្រទេសដ៏សមគួរ ។

៥- ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន ។

៦- កិរិយាតម្កល់ខ្លួនដោយប្រពៃ ។

៧- ភាវៈនៃបុគ្គលបានស្តាប់បានរៀនហើយដោយច្រើន ។

៨- សិល្បសាស្ត្រគឺសេចក្តីឆ្លៀវឆ្លាតក្នុងហត្ថកម្ម ។



៩- វិន័យដែលបុគ្គលសិក្សាដោយប្រពៃ ។

១០- វាចាដែលបុគ្គលពោលត្រឹមត្រូវ ។

១១- កិរិយាបំរើនូវមាតា ។

១២- កិរិយាបំរើនូវបិតា ។

១៣- សេចក្តីសង្គ្រោះដល់បុត្រ និង ភរិយា ។

១៤- ការងារទាំងឡាយដែលមិនច្របូកច្របល់ ។

១៥- កិរិយាបរិច្ចាគទាន ។

១៦- កិរិយាប្រព្រឹត្តនូវធម៌ ( កុសលកម្មបទ១០ ) ។

១៧- សេចក្តីសង្គ្រោះដល់ញាតិទាំងឡាយ ។

១៨- ការងារទាំងឡាយដែលមិនមានទោស ។

១៩- កិរិយាមិនត្រេកអរក្នុងបាប និង កិរិយាវៀរចាកបាប ។



២០- សេចក្តីសង្រួមចាកកិរិយាផឹកនូវទឹកស្រវឹង ។

២១- សេចក្តីមិនប្រមាទក្នុងធម៌ទាំងឡាយ ។

២២- សេចក្តីគោរពដល់បុគ្គលដែលគួរគោរព ។

២៣- កិរិយាប្រព្រឹត្តបន្ទាបខ្លួនឱ្យទន់ភ្លន់ ។

២៤- សេចក្តីសន្តោសចំពោះវត្ថុតាមមានតាមបាន ។

២៥- កតញ្ញុតា ការដឹងនូវគុណដែលបានធ្វើហើយ ។

២៦- កិរិយាស្តាប់នូវធម៌តាមកាល ។

២៧- សេចក្តីអត់ធន់ ( ខន្តិសំវរៈ ) ។

២៨- ភាវៈនៃបុគ្គលដែលប្រដៅបានដោយងាយ ។

២៩- កិរិយាបានឃើញបានជួបនូវសមណៈអ្នកស្ងប់រម្ងាប់នូវបាបទាំងឡាយ ។

៣០- កិរិយាសន្ទនានូវធម៌តាមកាលពេលវេលា ។

៣១- កិរិយាព្យាយាមដុតនូវបាបធម៌ក្នុងសន្តាន ។

៣២-កិរិយាប្រព្រឹត្តនូវព្រហ្មចរិយធម៌ ។

៣៣-កិរិយាឃើញនូវអរិយសច្ចធម៌ទាំងឡាយ ។

៣៤-កិរិយាជាក់ច្បាស់នូវព្រះនិព្វាន ( អរហត្តផល) ។

៣៥-ចិត្តដែលលោកធម៌ពាល់ត្រូវហើយមិនកម្រើក ញាប់ញ័រ ។

៣៦-មិនមានសេចក្តីសោកសៅ ។

៣៧-ប្រាសចាកនូវកិលេសទាំងពួង ។

៣៨-សភាពនៃចិត្តដែលក្សេមក្សាន្ត ។





✍សូមមនុស្សទាំងឡាយ ខំបដិបត្តិយកនូវមង្គលពិតប្រាកដបញ្ចុះទុកក្នុងសន្ដាន ដើម្បីបានបណ្ដេញនូវមង្គលភ្ញាក់ផ្អើលទាំងអស់ ឱ្យចេញអំពីគំនិត សូមឱ្យហឫទ័យនៃពុទ្ធបរិស័ទ បានជាភាជនៈពេញដោយមង្គល ៣៨ប្រការ កុំគប្បីក្លាយជាប្រការដទៃឡើយ ដោយគុណានុភាពនៃធម្មទាននេះឯងហោង ។





## ស្ថានីយវិទ្យុផ្សព្វផ្សាយព្រះធម៌
## ព្រះពុទ្ធសាសនា
## ដោយសហគមន៍ធម្មទាននៃពុទ្ធបរិស័ទ

| ខេត្ត~ក្រុង | ស្ថានីយវិទ្យុ | ពេល~ម៉ោង |
|---|---|---|
| រាជធានីភ្នំពេញ | -FM –99MHz<br>-AM738MHz<br>-FM –97MHz<br>-FM –98MHz<br>-FM –90MHz | -05h00 mn<br>-19h00 mn<br>-19h30 mn<br>-20h00 mn<br>-20h30 mn |
| ក្រុងព្រះសីហនុ | -FM –92MHz | -13h30 mn<br>-18h30 mn |
| ខេត្តបាត់ដំបង | -FM –91MHz | -17h30 mn |
| ក្រុងប៉ៃលិន | -FM –92MHz | -18h00 mn |